ព្រះរាជាណាចក្រកម្ពុជា

# ស្ថានភាពនៃភាពក្រីក្រនៅកម្ពុជាឆ្នាំ ២០០៤

## ការរកឃើញសំខាន់ៗ




ព្រះរាជាណាចក្រកម្ពុជា

ក្រសួងផែនការ

កុម្ភៈ ២០០៦

ព្រះរាជាណាចក្រកម្ពុជា

# ស្ថានភាពនៃភាពក្រីក្រនៅកម្ពុជាឆ្នាំ ២០០៤

## ការរកឃើញសំខាន់ៗ

**ក្រសួងផែនការ**

# ៣៨៦ មហាវិថីព្រះមុនីវង្សភ្នំពេញ រាជាណាចក្រកម្ពុជា

ទូរសព្ទ: (៨៥៥-២៣)២១៦ ១៩០/២១៧ ៤២៤

ទូរសារ: (៨៥៥-២៣) ២១៦ ១៩០/២១៨ ៨៩៥

អ៊ីមែល: pau.mop@forum.org.kh

# អារម្ភកថា

ស្ថានភាពនៃភាពក្រីក្រនៅកម្ពុជាឆ្នាំ ២០០៤ បង្ហាញពីការវិភាគសំខាន់ៗ នៃភាពក្រីក្រ និងពិនិត្យពីសញ្ញាដែលបញ្ចេញឱ្យឃើញពីនិន្នាការរបស់វា ដោយប្រើប្រាស់ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ ២០០៣/២០០៤ ។ ស្ថានភាពនៃភាពក្រីក្រនៅកម្ពុជាឆ្នាំ ២០០៤ បង្ហាញថាតើភាពក្រីក្រមានការប្រែប្រួលយ៉ាងណាជាមួយនឹងភូមិសាស្ត្រ និងថាតើភាពក្រីក្រមានឥទ្ធិពលយ៉ាងណាទៅលើភូមិទាំងឡាយ សហគមន៍ និងលក្ខណៈនៃគ្រួសារ ។ ដូច្នេះស្ថានភាពនៃភាពក្រីក្រផ្ដុកទៅដោយពតិមានមានតម្លៃ ដែលត្រូវការដើម្បីរៀបចំដោយប្រសិទ្ធភាពកម្មវិធី និងគោលនយោបាយទាំងឡាយដែលគាំទ្រភាពក្រីក្រ ។ ពតិមានក៏មានប្រយោជន៍ដែរ សំរាប់ត្រួតពិនិត្យនិងវាយតម្លៃភាពជឿនលឿន ក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស ។

ស្ថានភាពនៃភាពក្រីក្របច្ចុប្បន្នផ្ដល់នូវមូលដ្ឋានប្រពន្ធ័ពតិមានដ៏សម្បូរបែបមួយ លើការបែងចែកស្តង់ដារស់នៅនៃប្រជាជនកម្ពុជាគ្រប់រូប ។ ដោយហេតុនោះស្ថានភាពនៃភាពក្រីក្រ គាំទ្រការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ខ្លួន ។ ខ្ញុំមានក្ដីសោមនស្សរីករាយដោយដឹងថាការបកស្រាយដំបូងមួយរបស់ស្ថានភាពនៃភាពក្រីក្រ បានផ្ដល់នូវពតិមានយ៉ាងសំខាន់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិស៊ីជំរៅមួយរបស់កម្ពុជាសំរាប់ឆ្នាំ ២០០៦-២០១០ ។

ស្ថានភាពនៃភាពក្រីក្រឆ្នាំ ២០០៤ បានបង្ហាញពីអ្វីដែលកម្ពុជាអាចកាត់បន្ថយភាពក្រីក្របានលឿន តាមរយៈការសម្រេចបានកំណើនមួយ ដែលគាំទ្រខ្លាំងដល់ជនក្រីក្រក្នុងឆ្នាំទាំងឡាយខាងមុខ ។ ដោយសារមានការប្រែប្រួលខ្លាំងមួយ នៃយុទ្ធសាស្ត្រទាំងឡាយដែលផ្អែកលើចំណូល និងទ្រព្យសម្បត្តិដែលកាន់កាប់ដោយជនក្រីក្រ ដំណោះស្រាយតែឯកឯងមួយមិនអាចគ្រប់គ្រាន់ ដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជាបានទេ ។ ត្រូវមានការប្រយុទ្ធមួយដែលមានពហុមុខព្រួញ ។ លទ្ធផលទាំងឡាយគូសបញ្ជាក់ដែរ ពីបញ្ហាប្រឈមចំបងៗ នៃការពន្លឿនការកាត់បន្ថយភាពក្រីក្រក្នុងតំបន់ជនបទ តាមរយៈការទទួលយកសកម្មភាព យុទ្ធសាស្ត្រទាំងឡាយដែលបានកំណត់គោលដៅទុកជាមុន ។

ការវិភាគចង្អុលបង្ហាញពីតម្រូវការសំខាន់ សំរាប់គោលនយោបាយនិងសកម្មភាពទាំងឡាយ ដែលនឹងធានាថាកំណើនបានទៅដល់ និងពង្រីកឱកាសសំរាប់ជនក្រីក្រ ។ សំរាប់តម្រូវការនេះ យើងត្រូវកសាងទ្រព្យទាំងឡាយដែលទាមទារដោយជនក្រីក្រ ដូចជាការអប់រំ សុខភាពល្អប្រសើរ ការទទួលបានប្រភពនិងទីផ្សារ សម្លេងនិងអំណាច ការបញ្ចូលនិងចូលរួមក្នុងសង្គម ដើម្បីជួយដល់ជនក្រីក្រឱ្យមានធនធានសំរាប់ការពង្រីកឱកាសឱ្យមានកំណើន ។ ខ្ញុំជឿជាក់ថាការរកឃើញទាំងឡាយ របស់ស្ថានភាពនៃភាពក្រីក្រនឹងជួយកែប្រែ

យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រកម្ពុជា ឱ្យទៅជាសកម្មភាពសក្តិសិទ្ធិនិងមានប្រសិទ្ធភាព ដោយធ្វើឱ្យមានការផ្លាស់ប្តូរ សំរាប់ធានាឱ្យមាននិរន្តរភាពកំណើនសេដ្ឋកិច្ច និងផ្តល់ផលប្រយោជន៍ដល់ជនក្រីក្រ ។

ក្រសួងផែនការសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះការគាំទ្របច្ចេកទេស ហិរញ្ញវត្ថុ និងការគាំទ្រផ្សេងទៀតដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ធនាគារពិភពលោក (WB) ស្ថិតិស៊ុយអែតនិងភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA) សំរាប់ការដឹកនាំធ្វើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០០៣/២០០៤ និងសំរាប់ដំណើរការ និងការវិភាគទិន្នន័យដែលប្រមូលបាន ។ របាយការណ៍មូលដ្ឋានដែលបានរៀបចំឡើងដោយជំនាញការធនាគារពិភពលោក Dr. J.C. Knowles ដោយប្រើប្រាស់ទិន្នន័យពីវិធីសាស្ត្រ Recall និង Professors S. Johansson and S. Backlund ស្ថិតិស៊ុយអែត ដោយប្រើប្រាស់ទិន្នន័យពីវិធីសាស្ត្រ Diary នៃការអង្កេតសេដ្ឋកិច្ចសង្គមកិច្ច ២០០៣/២០០៤ បានផ្តល់នូវពតិមានយ៉ាងសំខាន់ក្នុងការរៀចំរបាយការណ៍ស្តីពីស្ថានភាពនៃភាពក្រីក្រ ។ ខ្ញុំសូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រចំពោះគាត់ ជាពិសេសចំពោះ Dr. Mustafa. K. Mujeri ជំនាញការតាមដាននិងវិភាគភាពក្រីក្ររបស់ UNDP នៅក្រសួងផែនការសំរាប់ការខិតខំប្រែងរបស់គាត់ក្នុងការរៀចំរបាយការណ៍ស្ថានភាពនៃភាពក្រីក្រ ។ ខ្ញុំសូមថ្លែងអំណរគុណដែរចំពោះ ឯកឧត្តម អ៊ូ ឱហាត រដ្ឋលេខាធិការក្រសួងផែនការ ឯកឧត្តម សន ស៊ីថន អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ លោកស្រី ហ៊ាង សៀក លី អគ្គនាយករង អគ្គនាយកដ្ឋានផែនការ និងមន្ត្រីផ្សេងទៀតក្នុងក្រសួងផែនការ សំរាប់ការខិតខំប្រឹងប្រែងរបស់គាត់ក្នុងការរៀបចំរបាយការណ៍នេះ ។

ខ្ញុំជឿជាក់ថារបាយការណ៍ស្តីពីស្ថានភាពនៃភាពក្រីក្រនេះ នឹងមានសារៈសំខាន់សំរាប់អ្នករៀបចំគោលនយោបាយ និងសំរាប់អ្នកទាំងឡាយផ្សេងទៀតដែលបានយកចិត្តទុកដាក់ជាមួយការអភិវឌ្ឍន៍នៅកម្ពុជា ។

**ឆាយ ថន**

ទេសរដ្ឋមន្ត្រី/រដ្ឋមន្ត្រី

ក្រសួងផែនការ

## I. ស្ថានភាពនៃភាពក្រីក្រឆ្នាំ ២០០៤_ការពិពណ៌នាជាប្រព័ន្ធមួយនៃភាពក្រីក្រនៅកម្ពុជា

១, ស្ថានភាពនៃភាពក្រីក្រគឺជាផ្នែកសំខាន់មួយនៃការវិភាគភាពក្រីក្ររបស់ក្រសួងផែនការ ។ ស្ថានភាពនៃភាពក្រីក្រកម្ពុជាឆ្នាំ ២០០៤ ពិពណ៌នាភាពក្រីក្រ និងពិនិត្យពីសញ្ញាដែលបញ្ចេញឱ្យឃើញពីនិន្នាការរបស់វា ដោយប្រើប្រាស់សូចនាករសំខាន់ៗទាំងឡាយ ។ ស្ថានភាពនៃភាពក្រីក្របង្ហាញថាតើភាពក្រីក្រ ប្រែប្រួលយ៉ាងណាតាមតំបន់ភូមិសាស្ត្រ ដូចជាតាមតំបន់ ឬខេត្តក្រុង ។ ស្ថានភាពនៃភាពក្រីក្របង្ហាញថាតើភាពក្រីក្រប្រែប្រួលយ៉ាងណាតាមភូមិ ឬតាមលក្ខណៈសហគមន៍ដូចជា ការចូលរៀន និងគិលានដ្ឋានសុខាភិបាល ឬតាមលក្ខណៈគ្រួសារដូចជាការអប់រំឬមុខរបរនៃមេគ្រួសារ ។ ការប្រើប្រាស់ទិន្នន័យពីការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ ២០០៤ ផ្តល់ការប្រៀបធៀបភាពក្រីក្រស៊ីជំរៅ បង្ហាញថាតើភាពក្រីក្របានប្រែប្រួលយ៉ាងណាក្នុងពេលកន្លងមក និងឆ្លងកាត់អន្តរតំបន់ និងក្រុមប្រជាជននៃសង្គមកម្ពុជា ។

### ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ច (CSES) ឆ្នាំ ២០០៣/២០០៤

២,វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានដឹកនាំការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០០៣/២០០៤ រវាងខែវិច្ឆិកាឆ្នាំ ២០០៣ និងខែមករាឆ្នាំ២០០៤ ។ ការអង្កេតគ្របដណ្តប់លើ ១៥,០០០សំណាកគំរូគ្រួសារក្នុងទូទាំងប្រទេស ។ ការអង្កេតបានប្រមូលទិន្នន័យលើការចំណាយប្រើប្រាស់ ដោយប្រើប្រាស់ទាំងវិធីសាស្ត្រ Diary និង Recall ។ នេះគឺជាការអង្កេតលើកទី ៥ ដែលបានដឹកនាំដោយវិទ្យាស្ថានជាតិស្ថិតិ បន្ទាប់ពីការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចក្នុងឆ្នាំ ១៩៩៣/៩៤ ១៩៩៦ ១៩៩៧ និង ១៩៩៩ ។ ទិសដៅសំខាន់នៃការអង្កេតគឺដើម្បីប្រមូលពត៌មានស្ថិតិ ស្តីពីស្តង់ដារស់នៅនៃជនកម្ពុជា និងប៉ាន់ស្មានភាពក្រីក្រក្នុងប្រទេស ។

### ភាពក្រីក្រប៉ាន់ស្មានតាមរយៈការអង្កេតទាំងឡាយមិនអាចប្រៀបធៀបបានដោយផ្ទាល់

៣, ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចដែលបានធ្វើឡើងនៅកម្ពុជា មិនអាចប្រៀបធៀបបានទាំងស្រុងទេ ដោយសារមូលហេតុច្រើនយ៉ាង ។ ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ច ឆ្នាំ ១៩៩៣/៩៤ គ្របដណ្តប់តែ ៥៩ ភាគរយនៃភូមិ និង ៦៨ ភាគរយនៃគ្រួសារនៅទូទាំងប្រទេស ដោយសារបញ្ហាសន្តិសុខនៅពេលនោះ ។ ក្នុងការអង្កេតជាបន្តបន្ទាប់ ការគ្របដណ្តប់បានកើនឡើងជាលំដាប់ ។ ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ ២០០៣/០៤ គឺជាការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាលើកទី ១ ដែលមានសំណាកគំរូគ្របដណ្តប់ទូទាំងប្រទេស ។ ការអង្កេតនេះយកតាមសំណាកគំរូស្តីពីការធ្វើជំរឿនជាទូទៅនៃប្រជាជនលើកទី ១ ដែលបានធ្វើឡើងនៅឆ្នាំ ១៩៩៨ ។ ទំនាក់ទំនងនៃការពង្រីកគំរោងសំណាកគំរូរបស់ការធ្វើអង្កេតជាបន្ទាប់កន្លងមក ភាពខុសគ្នាក្នុងគំរូអង្កេត ពេលវេលានៃការអនុវត្ត និងទិដ្ឋភាពទាំងឡាយផ្សេងទៀតជាច្រើន ធ្វើឱ្យអត្រាភាពក្រីក្រដែលបានប៉ាន់ស្មានមិនអាចធ្វើកាប្រៀបធៀបបាន ។ ជាលទ្ធផល ការផ្លាស់ប្តូរទាំងឡាយក្នុងភាពក្រីក្រ ចាប់តាំងពីឆ្នាំ ១៩៩០ មកមិនអាចត្រូវបានទទួលដោយផ្ទាល់ពីតួលេខទាំងនោះ ។

### ការប្រៀបធៀបភាពក្រីក្រគឺធ្វើក្នុងក្របខណ្ឌឆ្នាំ ១៩៩៣/៩៤

៤. ដោយសារការមិនអាចប្រៀបធៀបបានរវាងការអង្កេតកន្លងមក ការប្រៀបធៀបភាពក្រីក្រក្នុងឆ្នាំ ២០០៤ត្រូវបានធ្វើឡើងតែក្នុងក្របខណ្ឌឆ្នាំមូលដ្ឋាន ១៩៩៣/៩៤ និងតែលើការប៉ាន់ស្មានឆ្នាំ ១៩៩៣/៩៤ ពីវិធីសាស្ត្រ Recall ។ នេះដោយសារការអង្កេតឆ្នាំ ១៩៩៣/៩៤ បានប្រមូលទិន្នន័យលើការចំណាយប្រើប្រាស់តាមរយៈវិធីសាស្ត្រ Recall តែឯង ។ ការប៉ាន់ស្មានភាពក្រីក្រតាមវិធីសាស្ត្រ Recall ឆ្នាំ ២០០៤ ត្រូវបានធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រ ដែលបានធានាភាពអាចប្រៀបធៀបបានជាអតិបរិមា ជាមួយការប៉ាន់ស្មានទាំងឡាយនៅឆ្នាំ ១៩៩៣/៩៤ ។ ដោយសារសំណាកគំរូពេញ ប៉ាន់ស្មានសំរាប់ឆ្នាំ ២០០៤ គឺខុសគ្នាក្នុងភូមិសាស្ត្រគ្របដណ្តប់ ពីការប៉ាន់ស្មានឆ្នាំ ១៩៩៣/៩៤ តំបន់ភូមិសាស្ត្រដូចគ្នាដែលបានបញ្ចូលក្នុងអង្កេតឆ្នាំ ១៩៩៣ / ៩៤ ត្រូវបានប្រើ ដើម្បីវាយតម្លៃការផ្លាស់ប្តូរភាពក្រីក្រចាប់តាំងពីឆ្នាំ ១៩៩៣/៩៤ មក។

### ស្ថានភាពនៃភាពក្រីក្រលម្អិតឆ្នាំ ២០០៤ ដោយប្រើប្រាស់លទ្ធផលពីវិធីសាស្ត្រ Recall តែឯង

៥. ទោះបីមានភាពខុសគ្នាច្រើន ការប៉ាន់ស្មានភាពក្រីក្រឆ្នាំ ២០០៤ តាមវិធីសាស្ត្រ Diary និង Recall គឺប្រហាក់ប្រហែលគ្នា ។ សន្ទស្សន៍រាប់ចំនួនមនុស្សនៃភាពក្រីក្រសំរាប់ប្រជាជនកម្ពុជាសរុប តាមវិធីសាស្ត្រ Diary គឺ ៣៥,៩ ភាគរយក្នុងឆ្នាំ ២០០៤ ធៀបជាមួយ ៣៤,៧ ភាគរយតាមវិធីសាស្ត្រ Recall។ ក្នុងទស្សនៈនេះស្ថានភាពនៃភាពក្រីក្រលម្អិតរបស់កម្ពុជាសំរាប់ឆ្នាំ ២០០៤ ត្រូវបានបង្ហាញដោយប្រើលទ្ធផល នៃវិធីសាស្ត្រ Recall។ ការធ្វើរបៀបនេះសម្រួលដែរដល់ការប្រៀបធៀបជាមួយឆ្នាំ ១៩៩៣/៩៤ ពេលដែលទិន្នន័យត្រូវបានប្រមូលដោយប្រើវិធីសាស្ត្រ Recall តែឯង ។

## II. ចំណុចគោលថ្មី និងភាពក្រីក្រប៉ាន់ស្មានដោយប្រើ Diary ទិន្នន័យ

៦. វិធីសាស្ត្រ Diary ប៉ាន់ស្មានភាពក្រីក្រដោយប្រើទិន្នន័យពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ ២០០៤ ខុសគ្នាពីការប៉ាន់ស្មានក្នុងវិធីសាស្ត្រ Recall លើចំណុចខ្លះៗ ។ ភាពខុសគ្នាចម្បងខ្លះៗរួមមាន: (១) វិធីសាស្ត្រ Diary ប៉ាន់ស្មានភាពក្រីក្រដោយផ្អែកលើបញ្ជីម្ហូបអាហារ និងមិនមែនម្ហូបអាហារនៃបញ្ជភាគទី ២ ជាជាងបញ្ជភាគទី ៣ ដែលបានប្រើសំរាប់ការប៉ានស្មានដោយវិធីសាស្ត្រ Recall ក្នុងការបែងចែកនៃការចំណាយប្រើប្រាស់សរុបរបស់មនុស្សម្នាក់ៗក្នុង (២) វិធីសាស្ត្រ Diary ប៉ាន់ស្មានដោយប្រើ an adult-equivalent scale ដើម្បីធ្វើការប្រៀបធៀបគ្រួសារ តាមរយៈភាពខុសគ្នាក្នុងទំហំនិងសមាសភាព ចំណែកឯវិធីសាស្ត្រ Recall ប៉ាន់ស្មានដោយផ្អែកលើការប្រើប្រាស់ម្នាក់ៗ (៣) វិធីសាស្ត្រ Diary ទទួលយកការប៉ាន់ស្មានពីសន្ទស្សន៍ថ្លៃនៅក៏រិតគ្រួសារសំរាប់ម្ហូបអាហារដោយផ្អែកលើតំលៃឯកត្តា ផ្ទុយទៅវិញវិធីសាស្ត្រ Recall ប៉ាន់ស្មានដោយប្រើតម្លៃនៅថ្នាក់ភូមិ (៤) វិធីសាស្ត្រ Diary ប៉ាន់ស្មានដោយប្រើតម្លៃជួលផ្ទះដែលត្រូវបានកែតម្រូវសំរាប់គុណភាពខុសៗគ្នា និង (៥) វិធីសាស្ត្រ Diary ប៉ាន់ស្មានដោយប្រើការចុះតម្លៃនៃរបស់

ប្រើយូរអង្វែរបស់គ្រួសារ ។ ម្យ៉ាងទៀតវិធីសាស្ត្រ Recall ប៉ាន់ស្មានដោយប្រើតម្លៃថ្លៃនៃរបស់ប្រើប្រាស់យូរអង្វែងដែលបានទិញក្នុង១២ ខែកន្លងមក ។

## ការចំណាយប្រើប្រាស់ខាំងឆ្ងាយបង្ហាញពីភាពខុសគ្នាយ៉ាងធំតាមតំបន់

**៧.** ចំណាយប្រើប្រាស់ជាមធ្យមប្រចាំថ្ងៃ សំរាប់មនុស្សម្នាក់ៗតាមគ្រួសារនៅកម្ពុជាគឺ ៣,៦០៦ រៀល (០,៩០ដុល្លាអាមេរិក) ក្នុងឆ្នាំ ២០០៤ គិតតាមថ្លៃមធ្យមនៅភ្នំពេញឆ្នាំ ២០០៤ ។ ចំណាយប្រើប្រាស់ជាមធ្យមក្នុងមនុស្សពេញវ័យម្នាក់ក្នុងមួយថ្ងៃគឺខ្ពស់ជាងបន្តិចប្រហែល៣,៧២០រៀល(០,៩៣ដុល្លាអាមេរិក)។ ការប៉ាន់ស្មានតាមតំបន់ បង្ហាញភាពខុសគ្នាច្រើនគួរសមក្នុងកំរិតស្តង់ដារស់នៅក្នុងតំបន់ទាំង ៣ ។ សំរាប់ទិន្នន័យពី Diary ចំណាយម្នាក់ក្នុងមួយថ្ងៃ គឺ ៣,១៦៤ រៀល (០,៧៩ ដុល្លាអាមេរិក)ក្នុងតំបន់ជនបទ ៥,០០៧រៀល (១,២៥ ដុល្លាអាមេរិក) ក្នុងតំបន់ទីប្រជុំជនផ្សេងទៀត និង៨,៣២៤រៀល (២,០៨ដុល្លាអាមេរិក)នៅទីប្រជុំជនភ្នំពេញ ។

## ម្ហូបអាហារគឺជាការចំណាយប្រើប្រាស់សំខាន់សំរាប់គ្រប់ជនកម្ពុជា

**៨.** ចំណែកនៃម្ហូបអាហារក្នុងការចំណាយសរុបគឺ ៥៥ភាគរយ សម្រាប់គ្រប់ជនកម្ពុជា ។ ការចំណាយនេះប្រែប្រួលពី ៣៩ ភារយនៅភ្នំពេញ ទៅ ៤៨ ភាគរយ ក្នុងតំបន់ទីប្រជុំជនផ្សេងទៀត និង៥៩ ភាគរយក្នុងតំបន់ជនបទ ។ ភាពខុសគ្នាខ្លះត្រូវបានគិតទុកតាំងពីចំណូល និងកំរិតស្តង់ដារស់នៅមានកំរិតខ្ពស់នៅភ្នំពេញ បន្ទាប់មកនៅទីប្រជុំជនផ្សេងទៀត និងតំបន់ជនបទ ។

### រូបភាពទី ១:ចំណែកម្ហូបអាហារតាមតំបន់ ឆ្នាំ ២០០៤
### (ភាគរយ)




**ប្រភព:** S. Johansson and S. Backlund,គំរូថ្មីមួយនៃភាពក្រីក្រប៉ាន់ស្មានសំរាប់កម្ពុជាឆ្នាំ២០០៤ ដោយផ្អែកលើទិន្នន័យ Diary ២០០៤ (mimeo) វិទ្យាស្ថានជាតិស្ថិតិ, ២០០៥ និងស្ថានភាពនៃភាពក្រីក្រមួយនៅកម្ពុជា២០០៤, ក្រសួងផែនការ, កុម្ភ:២០០៦

**៩.** ធញ្ញជាតិគឺជាក្រុមម្ហូបអាហារធំជាងគេ ទាំងគិតជាតម្លៃ (៣១ ភាគរយ) និងគិតជាថាមពល (៦៥ ភាគរយ)។ តំបន់ទាំង ៣ បង្ហាញឱ្យឃើញភាពខុសគ្នាក្នុងចំណែកខ្លះ ។ ចំណែកធញ្ញជាតិក្នុងការចំណាយលើម្ហូប

អាហារសរុបគឺមានតែ ១១ភាគរយនៅភ្នំពេញ ធៀបនឹង ២៥ ភាគរយក្នុងតំបន់ទីប្រជុំជនផ្សេងទៀត និង ៣៥ ភាគរយនៅតំបន់ជនបទ ។

## កម្ពុជាទទួលថាមពលភាគច្រើនពីធញ្ញជាតិ

១០. កម្ពុជាទទួលស្ទើរតែ ២/៣ នៃថាមពលពីធញ្ញជាតិ ។ម្យ៉ាងទៀតចំណែកនៃធញ្ញជាតិក្នុងថាមពលសរុបបានប្រែប្រួលពី ៣៤ ភាគរយនៅភ្នំពេញទៅ ៥៨ ភាគរយក្នុងតំបន់ទីប្រជុំជនផ្សេងទៀត និង ៦៩ភាគរយក្នុងតំបន់ជនបទ ។ ជាមួយភាពពឹងពាក់ខ្ពស់ខ្លះសំរាប់ថាមពលលើធញ្ញជាតិ វាហាក់ដូចជាថាជនក្រីក្រជាពិសេសក្នុងតំបន់ជនបទ នឹងអាចត្រូវបានរងគ្រោះពីកង្វះប្រូតេអ៊ីន និងមីក្រូសារជាតិ (nmocro-nutrient)។ នេះមានទំនាក់ទំនង សំខាន់សំរាប់អាហារូបត្ថម្ភ និងការយល់ដឹងពីការអភិវឌ្ឍន៍ក្នុងចំណោមកុមារ ។

១១. ថាមពលប្រចាំថ្ងៃជាមធ្យមសំរាប់មនុស្សពេញវ័យគឺមិនខុសគ្នាច្រើនទេរវាងភ្នំពេញ (២,៤០៦ កាឡូរី) តំបន់ទីប្រជុំជនផ្សេងទៀត (២,៥១៥ កាឡូរី)និងតំបន់ជនបទ (២,៥០៤កាឡូរី) ទោះបីមានភាពខុសគ្នាច្រើនក្នុងចំណូលរវាងតំបន់ទាំង ៣ ។

## ភាពខុសគ្នាយ៉ាងធំក្នុងការប្រើប្រាស់ថាមពលរវាងបញ្ចភាគទាំងឡាយ

១២. ភាពខុសគ្នាក្នុងការប្រើប្រាស់ថាមពលក្នុងចំណោមបញ្ចភាគទាំង ៥ គឺមានទំហំធំធេង ។ភាពខុសគ្នានេះចាប់ផ្តើមពី ១,៤៧៦ កាឡូរី សំរាប់មនុស្សពេញវ័យម្នាក់ក្នុងមួយថ្ងៃក្នុងបញ្ចភាគក្រីក្របំផុត ទៅ ៤,០០៦ កាឡូរីក្នុងបញ្ចភាគមានបំផុត ។ ថាមពលជាមធ្យមគឺតិចជាង ១,៥០០ កាឡូរីសំរាប់មនុស្សពេញវ័យម្នាក់ក្នុងមួយថ្ងៃនៃបញ្ចភាគក្រីក្របំផុត បញ្ជាក់ថាមនុស្សពីគ្រួសារទាំងនេះរងគ្រោះពីការអត់ឃ្លានជាប្រចាំ ។

រូបភាពទី ២:ថាមពលមធ្យមសំរាប់មនុស្សពេញវ័យក្នុងមួយថ្ងៃ, ២០០៤




ប្រភព: S. Johansson and S. Backlund,គំរូថ្មីមួយនៃភាពក្រីក្របាន់ស្មានសំរាប់កម្ពុជាឆ្នាំ២០០៤ ដោយផ្អែក លើទិន្នន័យ Diary ២០០៤ (mimeo) វិទ្យាស្ថានជាតិស្ថិតិ, ២០០៥ និងស្ថានភាពនៃភាពក្រីក្រមួយនៅកម្ពុជា២០០៤, ក្រសួងផែនការ, កុម្ភៈ២០០៦

## ថមពលពីធញ្ញជាតិគឺថោកបំផុត

១៣. តម្លៃក្នុងមួយកាឡូរីគឺថោកបំផុតសំរាប់ធញ្ញជាតិ (០,៣៩ រៀល) បន្ទាប់មកគឺ ផ្លែឈើ (០,៦៨ រៀល) ម្ហូបបរិភោគនៅផ្ទះ (០,៨១ រៀល) ម្ហូបបរិភោគនៅក្រៅផ្ទះ (០,៨៣រៀល) ។ តម្លៃមធ្យមក្នុងមួយកាឡូរីគឺ ១,៣៣ រៀល នៅទីក្រុងភ្នំពេញ ធៀបជាមួយនិង ០,៩៩រៀលនៅតាមទីប្រជុំជនផ្សេងទៀត និង ០,៧៧ រៀលនៅតំបន់ជនបទ ។

១៤. តម្លៃមួយឯកត្តានៃកាឡូរីពីធញ្ញជាតិ គឺមានតម្លៃថោកនៅតំបន់ជនបទ (០,៣៧រៀល) ជាងនៅទីក្រុងភ្នំពេញ (០,៤៥រៀល) ឬតំបន់ទីប្រជុំជនផ្សេងទៀត (០,៤២រៀល) ។ តម្លៃថោកនៃធញ្ញជាតិនេះនៅតំបន់ជនបទគឺមានសារៈសំខាន់ណាស់ ដោយសារធញ្ញជាតិគឺជាមុខម្ហូបសំខាន់ជាងគេសម្រាប់ជនកម្ពុជាភាគច្រើន និងជាទូទៅសំរាប់ប្រជាជនក្រីក្រ ។

### ផ្ទះគឺជារបស់សំខាន់នៃការចំណាយប្រើប្រាស់មិនមែនម្ហូបអាហារសំរាប់ជនកម្ពុជាទាំងអស់

១៥. ផ្ទះ(រួមមានជួល ថែរក្សា និងជួសជុល) គឺជារបស់សំខាន់តំណាងឱ្យ ៤៣ ភាគរយនៃការចំណាយមិនមែនម្ហូបអាហារសរុប សំរាប់ជនកម្ពុជាទាំងអស់ ។ ជាមធ្យមលំនៅដ្ឋាននៅភ្នំពេញ ចំណាយ ៤៣,៥ ភាគរយនៃការចំណាយមិនមែនម្ហូបអាហារសរុបសំរាប់ផ្ទះ ធៀបជាមួយ ៤៩,១ ភាគរយនៅតំបន់ទីប្រជុំជនផ្សេងទៀត និង ៤១ ភាគរយនៅតំបន់ជនបទ ។

### ការចំណាយសំរាប់ការថែរក្សាសុខភាព និងការអប់រំគឺទាបខ្លាំង

១៦. សំរាប់ចំណាយផ្ទាល់ទាក់ទងទៅនឹងការអភិវឌ្ឍន៍ធនធានមនុស្ស ចំណែកទាំងឡាយគឺមានកំរិតទាប ។ ចំណែកនៃការថែរក្សាសុខភាព ក្នុងការចំណាយមិនមែនម្ហូបអាហារសរុបគឺ ៤,៥ ភាគរយសំរាប់ជនកម្ពុជាទាំងអស់ ។ ដូចគ្នាដែរចំណែកនៅភ្នំពេញគឺ ៣ ភាគរយ នៅតាមតំបន់ទីប្រជុំជនផ្សេងទៀត ២,៤ភាគរយ ហើយខ្ពស់ខ្លាំង ៥,៣ ភាគរយនៅតំបន់ជនបទ ។ នេះបង្ហាញពីបន្ទុកមិនសមាមាត្រមួយនៃតម្លៃថែរក្សាសុខភាពសំរាប់ប្រជាជននៅជនបទ ។ ចំណែកដ៏ធំនៃការចំណាយមិនមែនម្ហូបអាហារ លើការថែរក្សាសុខភាពសំរាប់ប្រជាជននៅជនបទ បង្ហាញដែរពីការផ្សាភ្ជាប់មួយរវាងភាពអត់ឃ្លាននិងសុខភាពនៅកម្ពុជា ។ ទំនាក់ទំនងនៃផលប៉ះពាល់ទាំងឡាយនេះ ដល់សតិបញ្ញានិងការបញ្ជូនភាពអត់ឃ្លាននិងភាពក្រីក្រ ទៅជំនាន់ក្រោយតម្រូវឱ្យមានការស្រាវជ្រាវបន្តទៀត ដើម្បីរៀបចំយុទ្ធសាស្ត្រឱ្យបានសមស្រប ។ ចំណែកនៃការអប់រំក្នុងការចំណាយមិនមែនម្ហូបអាហារសរុបគឺមានតែ ១,៨ ភាគរយសំរាប់ជនកម្ពុជាទាំងអស់ ដែលតិចជាងច្រើនចំណែកដូចគ្នាក្នុងការកំសាន្ត និងវប្បធម៌ (៦ភាគរយ) និងសូម្បីតែបារីគឺ (១,៩ ភាគរយ) ។ ចំណែកសំរាប់ការអប់រំនៅភ្នំពេញគឺ ៣,៩ ភាគរយ បន្ទាប់មក ២,១ ភាគរយក្នុងតំបន់ទីប្រជុំជនផ្សេងទៀត និងទាបបំផុតមួយតែ ១,៣ ភាគរយក្នុងតំបន់ជនបទ ។

### ការបែងចែកនៃចំណាយប្រើប្រាស់គឺលំអៀង

១៧. ចំណាយប្រើប្រាស់មធ្យមសំរាប់មនុស្សពេញវ័យក្នុងមួយថ្ងៃនៅកម្ពុជាគឺ ៣,៧២០ រៀល (០,៩៣ដុល្លា

អាមេរិក) ។ តម្លៃនេះសំរាប់បញ្ចភាគក្របំផុតគឺតែ ១,៣២២រៀល (0,៣៣ដុល្លាអាមេរិក)និងតិចជាងមួយដុល្លាសំរាប់គ្រប់បញ្ចភាគទាំងអស់ លើកលែងតែបញ្ចភាគមានបំផុតមួយគឺ ៩,0៦៨ រៀល(២,២៧ ដុល្លាអា-មេរិក) ។

**១៨,** ចំណែកនៃការចំណាយរបស់បញ្ចភាគក្របំផុត ក្នុងការបែងចែកចំណាយសរុបសំរាប់មនុស្សពេញវ័យម្នាក់ក្នុងមួយថ្ងៃគឺតែ ៧,១ ភាគរយ ចំណែកឯចំណែករបស់បញ្ចភាគមានបំផុតគឺ ៤៨,៧ ភាគរយ ។ នេះបង្ហាញថាស្ទើរតែពាក់កណ្តាលនៃការចំណាយសរុបរបស់ប្រទេស គឺបានសប្បាយចាយដោយ ២0 ភាគរយនៃជនកម្ពុជាដែលមានបំផុត ។

**១៩,** តម្លៃ Gini coefficient នៃការចំណាយប្រើប្រាស់សំរាប់មនុស្សពេញវ័យម្នាក់ក្នុងមួយថ្ងៃគឺ 0,៤0៣ សំរាប់កម្ពុជា ។ នេះបង្ហាញពីកំរិតខ្ពស់មួយនៃវិសមភាព ប្រៀបធៀបជាមួយប្រទេសជាច្រើនក្នុងតំបន់អាស៊ីអគ្នេយ៍ ។ ក្នុងចំណោមតំបន់ទាំងឡាយ តំបន់ទីប្រជុំជនផ្សេងទៀតមាន Gini coefficient (0,៤២៥)ខ្ពស់បំផុត បន្ទាប់មកតំបន់ជនបទ (0,៣៧២) និងភ្នំពេញ (0,៣៥១) ។ Gini coefficient ដែលបានគណនាពីសំណាកគំរូតាមភូមិសាស្ត្រដែលអាចប្រៀបធៀបបាន ដោយប្រើប្រាស់ទិន្នន័យ Recall ពីឆ្នាំ ១៩៩៣/៩៤ និង ២00៤ បង្ហាញថាវិសមភាពក្នុងការបែងចែក នៃការចំណាយសំរាប់មនុស្សម្នាក់បានកើនឡើងច្រើននៅតំបន់ជនបទ (ពី0,២៧ ទៅ 0,៣៣) ទោះបីយ៉ាងណា វិសមភាពនេះនៅតែទាបជាង វិសមភាពនៅទីក្រុងភ្នំពេញ ឬតំបន់ទីប្រជុំជនផ្សេងទៀត ។ នៅភ្នំពេញ វិសមភាពបានធ្លាក់ចុះបន្តិចបន្តួចពី 0,៣៩ មក 0,៣៧ រវាងឆ្នាំ ១៩៩៣/៩៤ និងឆ្នាំ២00៤ ចំណែកឯនៅតាមតំបន់ទីប្រជុំជនផ្សេងទៀត វាស្ថិតនៅថេរប្រហែល 0,៤៤ ។ ដូច្នេះភាពខុសគ្នាមួយក្នុងការប្រែប្រួលតាមតំបន់ជាក់លាក់ ក្នុងវិសមភាពនៃការចំណាយប្រើប្រាស់សំរាប់មនុស្សម្នាក់ ពិសេសក្នុងតំបន់ជនបទដែលប្រជាជនក្រីក្រជាង ៩0 ភាគរយរស់នៅ មានផលប៉ះពាល់យ៉ាងសំខាន់លើការកាត់បន្ថយភាពក្រីក្រ តាមតំបន់ផ្សេងៗទាំងឡាយនៃប្រទេស ។

រូបភាពទី៣: ការបែងចែកនៃការចំណាយប្រើប្រាស់សំរាប់មនុស្សពេញវ័យ, ២00៤




ប្រភព: S. Johansson and S. Backlund, គំរូថ្មីមួយនៃភាពក្រីក្រប៉ាន់ស្មានសំរាប់កម្ពុជាឆ្នាំ២00៤

ដោយផ្អែកលើទិន្នន័យ Diary ២០០៤ (mimeo) វិទ្យាស្ថានជាតិស្ថិតិ, ២០០៥ និងស្ថានភាពនៃភាពក្រីក្រមួយនៅកម្ពុជា២០០៤, ក្រសួងផែនការ, កុម្ភៈ២០០៦

## ជនកម្ពុជា ៤,៧ លាននាក់រស់នៅក្នុងភាពក្រីក្រ

**២០.** នៅឆ្នាំ ២០០៤,ក្នុងចំណោមប្រជាជនសរុប ១៣,០៤ លាននាក់ ៤,៧លាននាក់រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ។ ចំនួនជនក្រីក្ររស់នៅក្រោមបន្ទាត់ភាពក្រីក្រម្ហូបអាហារគឺ ២,៦ លាននាក់ ។ បន្ទាត់ភាពក្រីក្រសរុបដែលបានប៉ាន់ស្មានគឺ ២,១២៤ រៀល (០,៥៣ដុល្លាអាមេរិក) ក្នុងតម្លៃមធ្យមនៅភ្នំពេញឆ្នាំ ២០០៤ និងបន្ទាត់ភាពក្រីក្រម្ហូបអាហារគឺ ១,៦៨៤ រៀល (០,៤២ ដុល្លាអាមេរិក) ។ តម្លៃបន្ទាត់ភាពក្រីក្រមិនមែនម្ហូបអាហារគឺ ៤៤០រៀល (០,១០ដុល្លាអាមេរិក) ។

**២១.** សន្ទស្សន៍រាប់ចំនួនមនុស្ស ឬភាគរយនៃប្រជាជនដែលមានចំណាយប្រើប្រាស់សំរាប់ម្នាក់ស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រនៅកម្ពុជាគឺ ៣៥,៩ ភាគរយនៅឆ្នាំ ២០០៤ ។ ដូចគ្នាដែរ ២០ភាគរយនៃប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រម្ហូបអាហារ ។ មានរង្វាស់សំខាន់២ផ្សេងទៀតនៃភាពក្រីក្រ ។ សន្ទស្សន៍គំលាតភាពក្រីក្រ *poverty gap index* វាស់វែងជំរៅនៃភាពក្រីក្រ ។ នេះគឺជាផលដកមធ្យមលើប្រជាជនសរុប រវាងចំណាយប្រើប្រាស់សំរាប់មនុស្សម្នាក់និងបន្ទាត់ភាពក្រីក្រ ។ គម្លាតភាពក្រីក្រមានតម្លៃសូន (០) ចង្អុលបង្ហាញថាប្រជាជន ទាំងអស់រស់នៅលើបន្ទាត់ភាពក្រីក្រ ។ ម្យ៉ាងទៀតទ្វេគុណ *squared* សន្ទស្សន៍គំលាតភាពក្រីក្រវាស់វែងភាពធ្ងន់ធ្ងរនៃភាពក្រីក្រ ។ នេះគឺជាគំលាតភាពក្រីក្រដែលបានធ្វើទ្វេគុណ មុនពេលវាដល់ក៏រិតមធ្យម ដូច្នេះ ការផ្តល់ weight ធំដើម្បីធ្វើឱ្យគំលាតភាពក្រីក្រកាន់តែធំឡើង ។ សន្ទស្សន៍គំលាតភាពក្រីក្រគឺ ៩,២ភាគរយ ចំណែកឯទ្វេគុណ សន្ទស្សន៍គំលាតភាពក្រីក្រគឺ ៣,៤ភាគរយសំរាប់កម្ពុជា ។ សំរាប់បន្ទាត់ភាពក្រីក្រម្ហូបអាហារ សន្ទស្សន៍គំលាតភាពក្រីក្រគឺ ៤,៣ភាគរយ និងសន្ទស្សន៍ភាពក្រីក្រធ្ងន់ធ្ងរគឺ ១,៤ភាគរយ ។

តារាង ១: ភាពក្រីក្រនៅកម្ពុជាឆ្នាំ ២០០៤

| | កម្ពុជា | ក្រុងភ្នំពេញ | តំបន់ទីប្រជុំជនផ្សេងទៀត | តំបន់ជនបទ |
|---|---|---|---|---|
| **បន្ទាត់ភាពក្រីក្រម្ហូបអាហារ** | | | | |
| សន្ទស្សន៍រាប់ចំនួនមនុស្ស (%) | 20.0 | 1.0 | 11.4 | 22.2 |
| សន្ទស្សន៍គំលាតភាពក្រីក្រ (%) | 4.3 | 0.2 | 2.2 | 4.8 |
| ទ្វេគុណសន្ទស្សន៍គំលាតភាពក្រីក្រ (%) | 1.4 | 0.0 | 0.7 | 1.6 |
| **បន្ទាត់ភាពក្រីក្រសរុប** | | | | |

| | | | | |
|---|---|---|---|---|
| សន្ទស្សន៍រាប់ចំនួនមនុស្ស (%) | 35.9 | 2.4 | 20.9 | 39.7 |
| សន្ទស្សន៍គំលាតភាពក្រីក្រ (%) | 9.2 | 0.4 | 5.1 | 10.2 |
| ទ្វេគុណសន្ទស្សន៍គំលាតភាពក្រីក្រ (%) | 3.4 | 0.1 | 1.8 | 3.8 |
| ចំនួនជនក្រីក្រដែលបានប៉ានស្មាន | | | | |
| ប្រជាជនសរុប (000) | 13,035 | 610 | 1,417 | 11,008 |
| ចំនួនជនក្រីក្រម្ហូបអាហារ (000) | 2,607 | 6 | 162 | 2,439 |
| ចំនួនជនក្រីក្រ (000) | 4,685 | 15 | 296 | 4,374 |
| % ជនក្រីក្រម្ហូបអាហារ | 100 | 0.2 | 6.2 | 93.4 |
| % ជនក្រីក្រ | 100 | 0.3 | 6.3 | 93.4 |

ប្រភព: S. Johansson and S. Backlund,គំរូថ្មីមួយនៃភាពក្រីក្រប៉ាន់ស្មានសំរាប់កម្ពុជាឆ្នាំ២០០៤ ដោយផ្អែកលើ ទិន្នន័យ Diary ២០០៤ (mimeo) វិទ្យាស្ថានជាតិស្ថិតិ, ២០០៥ និងស្ថានភាពនៃភាពក្រីក្រមួយនៅកម្ពុជា២០០៤, ក្រសួងផែនការ, កុម្ភៈ២០០៦

### ភាពក្រីក្រកម្ពុជាគឺនៅតំបន់ជនបទ

**២២.** ភាពខុសគ្នាធំកើតមានឡើងក្នុងភាពក្រីក្ររវាងទីក្រុងភ្នំពេញ តំបន់ទីប្រជុំជនផ្សេងទៀត និងតំបន់ជនបទ ។ នៅទីក្រុងភ្នំពេញអត្រាបន្ទាត់ភាពក្រីក្រម្ហូបអាហារគឺ ១,០ភាគរយ និងអត្រាបន្ទាត់ភាពក្រីក្រសរុបគឺ ២,៤ ភាគរយ ។ អត្រាទាំងនេះគឺ ១១,៤ភាគរយ និង២០,៩ភាគរយក្នុងតំបន់ទីប្រជុំជនផ្សេងទៀត ។ ក្នុងតំបន់ជនបទ អត្រាបន្ទាត់ភាពក្រីក្រម្ហូបអាហារ និងអត្រាបន្ទាត់ភាពក្រីក្រសរុបគឺខ្ពស់ខ្លាំង ២២,២ភាគរយ និង៣៩,៧ ភាគរយ ។

**២៣.** ភាពក្រីក្រនៅកម្ពុជាគឺភាគច្រើនជាហេតុការណ៏មួយនៅជនបទ ។ ក្នុងចំណោមនៃជនក្រីក្រ ៤,៤ លាននាក់ (៩៣,៤ភាគរយ) រស់នៅក្នុងតំបន់ជនបទ ចំណែក ០,៣ លាននាក់ (៦,២ភាគរយ) រស់នៅតំបន់ទីប្រជុំជនផ្សេងទៀត ហើយមានតែ ១៥,០០០នាក់រស់នៅទីក្រុងភ្នំពេញ ។ ចំណែកនៃជនក្រីក្ររស់នៅក្រោមបន្ទាត់ភាពក្រីក្រម្ហូបអាហារក៏ដូចគ្នាដែរ ។ នេះបង្ហាញថាការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រនៅកម្ពុជាត្រូវតែទាក់ទងនឹងការកើនឡើងនៃការអភិវឌ្ឍន៏និងផលិតភាពរបស់សេដ្ឋកិច្ចនៅជនបទ ដើម្បីពន្លឿនកំណើននៃចំណូល និងឱកាសនៅជនបទ ។

## III. ស្ថានភាពនៃភាពក្រីក្រដោយប្រើទិន្នន័យ Recall

### តម្លៃបានកើនឡើងភាគច្រើននៅតំបន់ជនបទ តាំងពីឆ្នាំ១៩៩៣/៩៤

**២៤.** បន្ទាត់ភាពក្រីក្រដែលបានកែសំរួលសំរាប់ឆ្នាំ ២០០៤ បង្ហាញថាអតិផរណាត្រូវបានកើនឡើងយ៉ាងឆាប់នៅតំបន់ជនបទ ។ រវាងឆ្នាំ ១៩៩៣/៩៤ និង ឆ្នាំ២០០៤ តម្លៃម្ហូបអាហារបានកើនឡើង ៤,៦ ភាគរយរៀង

រាល់ឆ្នាំក្នុងតំបន់ជនបទ ធៀបជាមួយ ៤,២ ភាគរយនៅភ្នំពេញ និង ៤,៦ ភាគរយក្នុងតំបន់ទីប្រជុំជនផ្សេងទៀត ។ តម្លៃមិនមែនម្ហូបអាហារបានកើនឡើង ៤,៤ ភាគរយក្នុងតំបន់ជនបទ និង ៣,៨ភាគរយនៅភ្នំពេញ និង ៣,៦ ភាគរយក្នុងតំបន់ទីប្រជុំជនផ្សេងទៀត ។ តាមតម្លៃបច្ចុប្បន្នបន្ទាត់ភាពក្រីក្រ (សរុប) ឆ្នាំ ២០០៤ ត្រូវបានប៉ាន់ស្មាន ២,៣៥១ រៀល(០,៥៩ដុល្លារអាមេរិក) នៅទីក្រុងភ្នំពេញ ១,៩៥២រៀល (០,៤៩ ដុល្លារអាមេរិក) ក្នុងតំបន់ទីប្រជុំជនផ្សេងទៀត និង ១,៧៥៣ រៀល (០,៤៤ ដុល្លារអាមេរិក) ក្នុងតំបន់ជនបទ ។

រូបភាពទី៤: បន្ទាត់ភាពក្រីក្រដែលបានកែសំរួល ឆ្នាំ២០០៤
(តាមតម្លៃរៀលបច្ចុប្បន្ន)




ប្រភព: J.C. Knowles,,គំរូថ្មីមួយនៃភាពក្រីក្រប៉ាន់ស្មានសំរាប់កម្ពុជាឆ្នាំ១៩៩៣/៩៤ ទៅ២០០៤របាការណ៍សំរាប់ អង្គភាពប្រទេស EAS នៃធនាគារពិភពលោក,២០០៥ និងស្ថានភាពនៃ ភាពក្រីក្រមួយនៅកម្ពុជា២០០៤, ក្រសួងផែនការ, កុម្ភៈ២០០៦

## ចំណាយប្រើប្រាស់បានកើនឡើងសំរាប់ជនកម្ពុជាទាំងអស់ ប៉ុន្តែតំបន់ទីប្រជុំនិងនាក់មានបានទទួលចំណេញច្រើន

**២៥,** ក្នុងឆ្នាំ២០០៤ចំណាយប្រើប្រាស់ពិតរបស់មនុស្សម្នាក់ក្នុងគ្រួសារសំរាប់ទិន្នន័យ Recall ត្រូវបានប៉ាន់ស្មាន ២,៥៨៥ រៀល (០,៦៥ដុល្លា) សំរាប់កម្ពុជាទាំងមូល ។ តួលេខនេះគឺ ៥,៥០១ រៀល (១,៣៨ដុល្លា) នៅភ្នំពេញ , ៣,៣៨៩រៀល (០,៨៥ដុល្លា) ក្នុងតំបន់ទីប្រជុំជនផ្សេងទៀត និង២,១៧០រៀល (០,៥៤ដុល្លា) ក្នុងតំបន់ជនបទ ។

**២៦,** សំណាកគំរូតាមភូមិសាស្ត្រដែលអាចប្រៀបធៀបបាន បង្ហាញថាការចំណាយប្រើប្រាស់ពិតសំរាប់មនុស្សម្នាក់ ក្នុងគ្រប់ តំបន់ទាំង ៣ បានកើនឡើងរវាងឆ្នាំ ១៩៩៣/៩៤ និង២០០៤ ។ ការកើនឡើងខ្ពស់បំផុតបានកើតមានឡើង ក្នុងតំបន់ទី ប្រជុំជនផ្សេងទៀត បន្ទាប់មកគឺទីក្រុងភ្នំពេញនិងតំបន់ជនបទ ។ ចំណែកក្នុងការចំណាយសរុបបាន កើនឡើងសំរាប់ទីក្រុងភ្នំពេញ និងតំបន់ទីប្រជុំជនផ្សេងទៀត ជាមួយនេះចំណែកបានថយចុះសំរាប់តំបន់ជនបទ ។

រូបភាពទី៩: ការបែងចែកចំណាយប្រើប្រាស់តាមបញ្ចភាគប្រើប្រាស់ម្នាក់ៗ




ប្រភព: J.C. Knowles,,គំរូថ្មីមួយនៃភាពក្រីក្រប៉ាន់ស្មានសំរាប់កម្ពុជាឆ្នាំ១៩៩៣/៩៤ ទៅ២០០៤ របាការណ៍សំរាប់អង្គភាពប្រទេស EAS នៃធនាគារពិភពលោក.២០០៥ និងស្ថានភាពនៃ ភាពក្រីក្រមួយនៅកម្ពុជា២០០៤. ក្រសួងផែនការ. កុម្ភៈ២០០៦

២៧. តាមតម្លៃថេរ ការចំណាយប្រើប្រាស់ប្រចាំថ្ងៃមធ្យមសំរាប់មនុស្សម្នាក់ នៃបញ្ចភាគក្របំផុត ២០ ភាគរយគឺ៩២៧ រៀល (០,២៣ដុល្លាអាមេរិក) ក្នុងឆ្នាំ២០០៤ ។ ការចំណាយប្រើប្រាស់ដូចគ្នាសំរាប់បញ្ចភាគមានបំផុត២០ភាគរយគឺមាន ៦ ដងច្រើនជាង ៦,១៥១ រៀល (១,៥៤ដុល្លាអាមេរិក) ។ សំណាកគំរូដែលអាចប្រៀបធៀបបាន បង្ហាញថាការចំណាយប្រើប្រាស់មធ្យមពិតសំរាប់មនុស្សម្នាក់ បានកើនឡើងសំរាប់គ្រប់បញ្ចភាគ ទាំងអស់រវាងឆ្នាំ ១៩៩៣/៩៤ និង ២០០៤ ទោះបីយ៉ាងណាការចំណាយកើនឡើងខ្លាំងសំរាប់បញ្ចភាគមានបំផុត ។ សំរាប់បញ្ចភាគក្របំផុត ២០ភាគរយ ការចំណាយប្រើប្រាស់មធ្យមពិតសំរាប់មនុស្សម្នាក់បានកើនឡើងតែ ៨ ភាគរយ ចំណែកឯអត្រាទាំងឡាយដូចគ្នាបានកើនឡើងស្របគ្នាសំរាប់បញ្ចភាគខ្ពស់បំផុតទៅដល់ ៤៥ ភាគរយសំរាប់បញ្ចភាគមានបំផុត ។ ជាលទ្ធផល ចំណែកទាំងឡាយនៃការចំណាយប្រើប្រាស់របស់ក្រុមដែលក្រក្នុងការចំណាយប្រើប្រាស់សរុបរបស់ប្រទេស បានធ្លាក់ចុះរវាងឆ្នាំ ១៩៩៣/៩៤ និង ២០០៤ ដែលជាការនាំទៅរកវិសមភាពដ៏ខ្ពស់ ។

## ជនកម្ពុជាទាំងអស់ឥឡូវនេះអាចរៃលក ដើម្បីចំណាយច្រើនលើតម្រូវការមូលដ្ឋានមិនមែនម្ហូបអាហារ

២៨. ក្នុងឆ្នាំ ២០០៤ ចំណែកនៃម្ហូបអាហារក្នុងការចំណាយប្រើប្រាស់សរុបគឺ ៤២ ភាគរយនៅភ្នំពេញ ៥៧ ភាគរយនៅតាមតំបន់ទីប្រជុំជនផ្សេងទៀត និង ៦៥ ភាគរយក្នុងតំបន់ជនបទ ។ បើនិយាយពីបញ្ចភាគវិញ នៅពេលដែលបញ្ចភាគក្របំផុត ២០ ភាគរយបានចំណាយ ៧០ ភាគរយសំរាប់ម្ហូបអាហារ បញ្ចភាគមានបំផុតបានចំណាយតែ ៤៧ ភាគរយ ។ សំណាកគំរូដែលអាចប្រៀបធៀបបាន បង្ហាញថាមានការថយចុះចំណែកក្នុងម្ហូបអាហារគ្រប់តំបន់ទាំងអស់ និងសំរាប់គ្រប់បញ្ចភាគទាំងអស់ រវាងឆ្នាំ១៩៩៣/៩៤ និង ២០០៤ ។ នេះបង្ហាញថាសមត្ថភាព និងការចំណាយលើរបស់មិនមែនម្ហូបអាហារបានកើនឡើង ។ នេះ

បញ្ជាក់ថាជនកម្ពុជាទាំងអស់ ឥឡូវនេះអាចលៃលកដើម្បីចំណាយច្រើន ទៅលើតម្រូវការមូលដ្ឋានមិនមែនម្ហូបអាហារ ។

## ការចំណាយប្រើប្រាស់ផ្សេងៗតាមតំបន់ភូមិសាស្ត្រ និងខេត្តត្រូវបានកើនឡើង

**២៩.** មានភាពខុសគ្នាសំខាន់ៗច្រើន ក្នុងការចំណាយប្រើប្រាស់សំរាប់មនុស្សម្នាក់ នៅតាមតំបន់ភូមិសាស្ត្រ និងខេត្ត ។ ទាំងទីក្រុងនិងតំបន់ជនបទនៃភ្នំពេញ និងតំបន់ទីក្រុងក្នុងវាលទំនាបនៅទន្លេសាប និងតំបន់ឆ្នេរ មានកំរិតមធ្យមនៃការចំណាយប្រើប្រាស់ខ្ពស់ជាងការចំណាយមធ្យមថ្នាក់ជាតិ ។ បើនិយាយពីការចំណាយសំរាប់មនុស្សម្នាក់ តំបន់ខ្ពង់រាប/ភ្នំគឺជាតំបន់ក្របំផុត បន្ទាប់មកគឺទន្លេសាបនិងវាលទំនាប ។ ខេត្តទាំងឡាយដែលមានការចំណាយប្រើប្រាស់សំរាប់មនុស្សម្នាក់ទាបរួមមាន កំពង់ស្ពឺ កំពង់ធំ ស្វាយរៀង និងព្រៃវែង ចំណែកភ្នំពេញ ក្រុងព្រះស៊ីហនុ/កែប/កោះកុង និងកណ្តាលមានការចំណាយប្រើប្រាស់សំរាប់មនុស្សម្នាក់ខ្ពស់ខ្លាំង ជាងការចំណាយមធ្យមថ្នាក់ជាតិ ។

តារាងទី២: ការចំណាយប្រើប្រាស់សំរាប់មនុស្សម្នាក់ប្រចាំថ្ងៃតាមគ្រួសារតាមតំបន់ភូមិសាស្ត្រឆ្នាំ ២០០៤

(តាមតម្លៃរៀលថេរ)

| តំបន់ភូមិសាស្ត្រ | ការចំណាយប្រើប្រាស់សំរាប់មនុស្សម្នាក់[1] | | | **សមាមាត្រ** (មធ្យមថ្នាក់ជាតិ =100)[2] | | | ចំណែកក្នុងការចំណាយប្រើប្រាស់សរុប (%)[3] | | |
|---|---|---|---|---|---|---|---|---|---|
| | **ទីប្រជុំជន** | **ជនបទ** | **សរុប** | **ទីប្រជុំជន** | **ជនបទ** | **សរុប** | **ទីប្រជុំជន** | **ជនបទ** | **សរុប** |
| ភ្នំពេញ | 9,687 | 6,186 | 8,120 | 254.6 | 162.6 | 213.4 | 11.7 | 6.1 | 17.8 |
| វាលទំនាប | 6,320 | 3,467 | 3,583 | 166.1 | 91.1 | 94.2 | 2.9 | 37.7 | 40.7 |
| ទន្លេសាប | 4,844 | 3,009 | 3,286 | 127.3 | 79.1 | 86.4 | 5.8 | 20.3 | 26.1 |
| តំបន់ឆ្នេរ | 4,745 | 3,415 | 3,810 | 124.7 | 89.7 | 100.1 | 2.7 | 4.6 | 7.3 |
| ខ្ពង់រាប/ភ្នំ | 3,734 | 2,620 | 2,820 | 98.1 | 68.8 | 74.1 | 1.9 | 6.2 | 8.1 |
| កម្ពុជា | 6,341 | 3,355 | 3,805 | 166.6 | 88.2 | 100.0 | 25.1 | 74.9 | 100.0 |

**កំណត់ចំណាំ:** ១. តំលៃថេរជារៀលឆ្នាំ២០០៤ដែលបានកំណត់ជាមួយតំលៃភ្នំពេញឆ្នាំ ២០០៤=១០០។ ២. មានសមាមាត្រ (បានកំណត់ក្នុងភាគរយ)ទៅនឹងកំរិតមធ្យមជាតិនៃការចំណាយប្រើប្រាស់ (សរុបសំរាប់កម្ពុជា ៣,៨០៥ រៀល) ៣. ចំណែកជាភាគរយនៃការចំណាយប្រើប្រាស់ក្នុងគ្រួសារសរុប។

ប្រភព: J.C. Knowles,,គំរូថ្មីមួយនៃភាពក្រីក្រប៉ាន់ស្មានសំរាប់កម្ពុជាឆ្នាំ១៩៩៣/៩៤ ទៅ២០០៤ របាការណ៍សំរាប់អង្គភាពប្រទេស EAS នៃធនាគារពិភពលោក,២០០៥ និងស្ថានភាពនៃ ភាពក្រីក្រមួយនៅកម្ពុជា២០០៤, ក្រសួងផែនការ, កុម្ភៈ២០០៦

## វិសមភាពក្នុងចំណាយប្រើប្រាស់បានកើនឡើងខ្លាំងនៅតំបន់ជនបទ

៣០, ក្នុងឆ្នាំ២០០៤ វិសមភាពក្នុងចំណាយប្រើប្រាស់ដែលបានវាស់វែងដោយ Gini coefficient ត្រូវបានប៉ាន់ស្មាន 0,៤0 នៅកម្ពុជា ។ Gini coefficient នេះខ្ពស់ណាស់បើធៀបជាមួយប្រទេសជាច្រើននៅតំបន់អាស៊ីអគ្នេយ៍ ។ វិសមភាពចំណាយប្រើប្រាស់គឺខ្ពស់ខ្លាំងក្នុងតំបន់ទីប្រជុំជនផ្សេងទៀត បន្ទាប់មកគឺភ្នំពេញនិងតំបន់ជនបទ ។ សំណាកគំរូតាមភូមិសាស្ត្រដែលអាចប្រៀបធៀបបានបង្ហាញកំណើនមួយខ្លាំង ក្នុងវិសមភាពចំណាយប្រើប្រាស់នៅតំបន់ជនបទរវាងឆ្នាំ១៩៩៣/៩៤ និង២០០៤ ម្យ៉ាងទៀតវិសមភាពនេះនៅតែទាបជាងវិសមភាពនៅភ្នំពេញ ឬតំបន់ទីប្រជុំជនផ្សេងទៀត ។ ការកើនឡើងខ្លះក្នុងវិសមភាព ពិសេសក្នុងតំបន់ជនបទ មានផលប៉ះពាល់ចម្បងលើការកាត់បន្ថយភាពក្រីក្រ និងជាហេតុការណ៍មួយត្រូវយកចិត្តទុកដាក់ ។

## ភាពក្រីក្រប្រែប្រួលតាមតំបន់នាំងឡាយ

៣១, ក្នុងឆ្នាំ២០០៤, សន្ទស្សន៍ភាពក្រីក្រនៅកម្ពុជាគឺប្រហែល ៣៥ ភាគរយ ។ ភាពខុសគ្នាខ្លាំងក្នុងតំបន់ស្ថិត ក្នុងអត្រាភាពក្រីក្រ ។ ចំណែកឯប្រហែលតែ ៥ ភាគរយនៃអ្នករស់នៅភ្នំពេញគឺក្រីក្រ ជិត ២៥ភាគរយក្នុង តំបន់ទីប្រជុំជនផ្សេងទៀតគឺក្រ ។ ក្នុងតំបន់ជនបទ អត្រាភាពក្រីក្រគឺច្រើនជាង ៣៩ ភាគរយ ។ ក្នុងចំនួនជនក្រីក្រសរុប ជាង ៩១ភាគរយរស់នៅតំបន់ជនបទ ធៀបនឹង ៨ ភាគរយក្នុងតំបន់ទីប្រជុំជនផ្សេងទៀត និងតែ ១ ភាគរយនៅភ្នំពេញ ។

រូបភាពទី៦: ភាពក្រីក្រតាមតំបន់នៅកម្ពុជាឆ្នាំ២០០៤




ប្រភព: J.C. Knowles,,គំរូថ្មីមួយនៃភាពក្រីក្រប៉ាន់ស្មានសំរាប់កម្ពុជាឆ្នាំ១៩៩៣/៩៤ ទៅ២០០៤របាការណ៍សំរាប់អង្គភាពប្រទេស EAS នៃធនាគារពិភពលោក,២០០៥ និងស្ថានភាពនៃ ភាពក្រីក្រមួយនៅកម្ពុជា២០០៤, ក្រសួងផែនការ, កុម្ភៈ២០០៦

៣២. សមាមាត្រនៃជនកម្ពុជារស់នៅក្រោមបន្ទាត់ភាពក្រីក្រម្ហូបអាហារគឺ ២០ ភាគរយក្នុងឆ្នាំ២០០៤ ។ នៅភ្នំពេញអត្រាគឺ ៣ភាគរយ ធៀបនឹងប្រហែល១៤ភាគរយនៅតាមទីប្រជុំជនផ្សេងទៀត និង ២២ ភាគរយនៅតំបន់ជនបទ ។

៣៣. ក្នុងករណីនៃគំលាតភាពក្រីក្រ និងទ្វេគុណគំលាតភាពក្រីក្រវាស់វែងក្នុងតំបន់ទាំង ៣ បង្ហាញចំណាត់ថ្នាក់ដូចគ្នាសំរាប់ទាំងភាពក្រីក្រ និងបន្ទាត់ភាពក្រីក្រម្ហូបអាហារ ។ ទាំងនេះខ្ពស់ខ្លាំងក្នុងតំបន់ជនបទ បន្ទាប់មកនៅតាមតំបន់ទីប្រជុំជនផ្សេងទៀត ហើយនិងភ្នំពេញ ។

## ភាពក្រីក្របានធ្លាក់ចុះនៅកម្ពុជាតាំងពីឆ្នាំ ១៩៩៣/៩៤

៣៤. សំរាប់សំណាកគំរូតាមតំបន់ភូមិសាស្ត្រដែលអាចប្រៀបធៀបបាន សន្ទស្សន៍ភាពក្រីក្របានធ្លាក់ចុះពី ៣៩ ភាគរយក្នុងឆ្នាំ ១៩៩៣/៩៤ មក ២៨ ភាគរយក្នុងឆ្នាំ ២០០៤ ។ សន្ទស្សន៍ភាពក្រីក្រម្ហូបអាហារបានធ្លាក់ចុះពី ២០ ភាគរយ មក ១៤,២ ភាគរយក្នុងរយៈពេលដូចគ្នា ។ ភាពក្រីក្របានធ្លាក់ចុះក្នុងតំបន់ទាំង ៣ ប៉ុន្តែអត្រាកាត់បន្ថយមិនបានស្មើរគ្នា ។ តំបន់ជនបទនៅតែស្ថិតនៅក្នុងអត្រាភាពក្រីក្រមួយខ្ពស់ ។ ក្នុងឆ្នាំ ២០០៤ អត្រាភាពក្រីក្រក្នុង ៤១ ភាគរយនៃតំបន់ដែលមិនបានបញ្ចូលក្នុងការធ្វើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ១៩៩៣/៩៤គឺ ៤៥,៦ ភាគរយ ធៀបនឹង ២៨ ភាគរយចំពោះតំបន់ដែលបានបញ្ចូលក្នុងការអង្កេត ។ នេះបង្ហាញថាតំបន់ដែលមិនបានបញ្ចូលគឺងាយរងគ្រោះខ្លាំង និងត្រូវការការយកចិត្តទុកដាក់ជាសំខាន់ ក្នុងការខិតខំកាត់បន្ថយភាពក្រីក្រ ។

រូបភាពទី៧: ការប្រែប្រួលក្នុងភាពក្រីក្រនៅកម្ពុជា ១៩៩៣/៩៤ និង២០០៤

(ផ្អែកលើសំណាកគំរូអាចប្រៀបធៀបបាន)




**ប្រភព:** J.C. Knowles,,គំរូថ្មីមួយនៃភាពក្រីក្រប៉ាន់ស្មានសំរាប់កម្ពុជាឆ្នាំ១៩៩៣/៩៤ ទៅ២០០៤របាការណ៍សំរាប់អង្គភាពប្រទេស EAS នៃធនាគារពិភពលោក,២០០៥ និងស្ថានភាពនៃ ភាពក្រីក្រមួយនៅកម្ពុជា២០០៤, ក្រសួងផែនការ, កុម្ភៈ២០០៦

## ប្រអប់ទី ១:និន្នាការ និងវិសមភាពក្នុងភាពក្រីក្រនៅកម្ពុជា

អត្រារាប់ចំនួនមនុស្សក្រីក្រ ដែលផ្អែកលើការចំណាយប្រើប្រាស់នៅកម្ពុជា បានធ្លាក់ចុះក្នុង១០ទសវត្សរ៍កន្លងមក ទោះយ៉ាងណាអត្រាគឺស្ថិតនៅខ្ពស់ ៣៤,៧ភាគរយក្នុងឆ្នាំ២០០៤ ។ គំលាតភាពក្រីក្រនិងទ្វេគុណគំលាតភាពក្រីក្រ តាមរង្វាស់ yardsticks បង្ហាញការថយចុះដែរក្នុងភាពក្រីក្រ ។ ភាពជឿនលឿនក្នុងការកាត់បន្ថយសន្ទស្សន៍ភាពក្រីក្រត្រូវបានធ្វើទាំងក្នុងតំបន់ទីប្រជុំជននិងជនបទ ប៉ុន្តែជោគជ័យខ្លាំងគឺនៅទីក្រុងភ្នំពេញ ។ តំបន់ជនបទពិសេសអ្នករស់នៅទីកន្លែង ងាយរងគ្រោះ និងលក្ខណ:ភូមិសាស្ត្រលំបាក នៅតែមានអត្រាភាពក្រីក្រខ្ពស់ ហើយត្រូវការការយកចិត្តទុកដាក់ ពិសេសនិងបានកំណត់ទុក ។

ទិន្នន័យស្តីពីការចំណាយលើម្ហូបអាហារគំរូ អះអាងដែរពីការធ្លាក់ចុះក្នុងភាពក្រីក្រ ។ ទិន្នន័យសិក្សាពីការវិវត្តន៍នៃមនុស្ស Anthropometric ចង្អុលបង្ហាញពីភាពជឿនលឿន ក្នុងការកាត់បន្ថយអត្រាមរណភាពទារកនិងកុមារ ក៏ដូចជារង្វាស់រួមផ្សេងទៀតនៃអាយុកាលជីវិតរស់នៅ ។ សមិទ្ធិផលរបស់កម្ពុជា ក្នុងការកាត់បន្ថយលទ្ធភាពផ្តល់កំណើត ត្រូវបានធ្វើយ៉ាងត្រឹមត្រូវ ។ ភាពជឿនលឿនក្នុងការបង្កើនអក្ខរភាព និងការចុះឈ្មោះចូលរៀនត្រូវបានលើកទឹកចិត្ត ទោះបីអត្រាបោះបង់ចោលការសិក្សាខ្ពស់ និងគុណភាពនៃការអប់រំនៅជាមូលហេតុនៃកង្វល់ដែលលើកឡើង និងយកចិត្តទុកដាក់។

វិសមភាពក្នុងការចំណាយប្រើប្រាស់គឺខ្ពស់ខ្លាំងនៅកម្ពុជា ជាមួយនឹងសំណាកគំរូតាមតំបន់ភូមិសាស្ត្រដែលអាចប្រៀបធៀបបាន ចង្អាញពីការកើនឡើងមួយខ្ពស់ក្នុងវិសមភាពនៅតំបន់ជនបទ រវាងឆ្នាំ១៩៩៣/៩៤ និង២០០៤។ ថ្វីបើគ្រប់បញ្ចូភាគចំណាយប្រើប្រាស់ទាំងអស់បានសម្រេច កំណើនបានផ្តល់ផលប្រយោជន៏ច្រើនដល់អ្នកដែលសម្បូរដោយទ្រព្យធន ជាងក្រុមអ្នកក្រ ។ កំណើននៅតំបន់ជនបទហាក់ដូចមានមូលដ្ឋានតូចចង្អៀតជាងតំបន់ទីប្រជុំជន ។

ជនក្រីក្រនៅកម្ពុជាមានលក្ខណ:ដែលស្រដៀងទៅនឹងលក្ខណៈនៃជនក្រីក្រក្នុងប្រទេសដែលមានចំណូលទាប ។ ក្នុងចំនួនសរុបនៃជនក្រីក្រ ជាង៩០ភាគរយរស់នៅតំបន់ជនបទ ធ្វើឱ្យភាពក្រីក្រក្លាយទៅជាហេតុការណ៍ដ៏ធំនៅតំបន់ជនបទ ។ នេះបញ្ជាក់ថាភាពក្រីក្ររបស់កម្ពុជាមានឫសគុលធំមួយក្នុងផ្នែកកសិកម្ម ដែលមានផលិតភាពទាប និងមានកំណើនកើនតិចតួច ប៉ុន្តែផ្តល់ជីវិតរស់នៅទៅដល់ភាគច្រើននៃប្រជាជនរបស់ប្រទេស ។

ជនក្រីក្រទំនងជាមានកំរិតអប់រំទាប ទទួលបានដីធ្លី និងទ្រព្យដែលផ្តល់ផលមានកំរិត ហើយប្រមូលផ្តុំក្នុងមុខរបរដែលមានកំរៃទាប ទាមទារកម្លាំងកាយនិងដែលមិនទាក់ទាញសង្គម ។ ជនក្រីក្រទទួលបានតិចតួចសេវាកម្មទំនើបនិងមិនទាក់ទាញចិត្ត ។ ជនក្រីក្ររស់នៅក្នុងផ្ទះទ្រុឌទ្រោម ជាមួយការទទួលបានតិតតួចសេវាមូលដ្ឋានដូចជា ទឹកស្អាតនិងអនាម័យដែលល្អប្រសើរ ។ ជនក្រីក្រច្រើនរស់នៅក្នុងគ្រួសារដែលមានមនុស្សច្រើន មានកូនច្រើននិងមានមេគ្រួសារដែលមានការអប់រំតិច ។ ដើម្បីឱ្យមានប្រសិទ្ធភាព គោលនយោបាយកាត់បន្ថយភាពក្រីក្រនៅកម្ពុជាត្រូវគិតគូពីពហុទំហំនៃការចាញ់ប្រៀបដែលជនក្រីក្រជួបប្រទះ ក្នុងការធ្វើឱ្យប្រសើរឡើងសភាពការណ៍របស់ខ្លួន ។

**ប្រភព:** ស្ថានភាពនៃភាពក្រីក្រមួយនៅកម្ពុជាឆ្នាំ២០០៤, ក្រសួងផែនការ, កុម្ភ:២០០៦

## ភាពក្រីក្រប្រែប្រួលខ្លាំងតាមតំបន់ភូមិសាស្ត្រ

៣៥.ក្នុងចំណោមតំបន់ភូមិសាស្ត្រ ភ្នំពេញមានអត្រាភាពក្រីក្រទាបបំផុត ៤.៦ភាគរយក្នុងឆ្នាំ២០០៤ ។ មួយចំណែកទៀត ខ្ពង់រាប/ភ្នំគឺជាតំបន់ក្របំផុតដោយមានអត្រាភាពក្រីក្រជាង ៥២ភាគរយ ។ ទន្លេសាបមានអត្រាភាពក្រីក្រ ៤៣ភាគរយ ធៀបជាមួយ ៣២ភាគរយក្នុងវាលទំនាប និង២៧ភាគរយក្នុងតំបន់ឆ្នេរ ។ វាលទំនាបមានចំណែកធំក្នុងភាពក្រីក្រ (៤០ភាគរយ)បន្ទាប់មកគឺទន្លេសាប (៣៧ភាគរយ) ខ្ពង់រាប/ភ្នំ (១៦ភាគរយ) និងតំបន់ឆ្នេរ ៦ភាគរយ) ។ ភាពក្រីក្រខ្ពស់ខ្លាំងក្នុងតំបន់ជនបទជាងក្នុងតំបន់ទីប្រជុំជនក្នុងគ្រប់តំបន់ទាំងអស់ ។

រូបភាពទី៨: ផែនទីភាពក្រីក្រតាមតំបន់ភូមិសាស្ត្រ




ប្រភព: ស្ថានភាពនៃភាពក្រីក្រមួយនៅកម្ពុជាឆ្នាំ២០០៤, ក្រសួងផែនការ, កុម្ភៈ ២០០៦

## ខេត្តទាំងឡាយដែលក្រីក្របំផុតរួមមានកំពង់ស្ពឺ កំពង់ធំ និងសៀមរាប,,,

៣៦, ក្នុងករណីនៃខេត្តទាំងឡាយ អត្រាភាពក្រីក្រក្នុងឆ្នាំ ២០០៤ ខ្ពស់ខ្លាំងក្នុងខេត្តកំពង់ស្ពឺ (៥៧,២ ភាគរយ) បន្ទាប់មកគឺកំពង់ធំ (៥២,៤ភាគរយ) និងសៀមរាប (៥១,៨ភាគរយ) ។ សន្ទស្សន៍ភាពក្រីក្រទាបខ្លាំងនៅភ្នំពេញ (៤,៦ ភាគរយ) កណ្ដាល (២២,២ភាគរយ)និងក្រុងព្រះសីហនុ/កែប/កោះកុង (២៣,២ភាគរយ) ។ គំលាតភាពក្រីក្រនិងសន្ទស្សន៍ភាពក្រីក្រធ្ងន់ធ្ងរក៏ស្របតាមនិន្នាការដូចគ្នាដែរ ។

## តារាងទី៣: ភាពក្រីក្របាន់ស្មានតាមខេត្តឆ្នាំ២០០៤

| ខេត្ត | សន្ទស្សន៍រាប់ចំនួនមនុស្សក្រីក្រ (%) | សន្ទស្សន៍គំលាតភាពក្រីក្រ (%) | ទ្វេគុណសន្ទស្សន៍គំលាតភាពក្រីក្រ (%) |
|---|---|---|---|
| **i) តំបន់ភ្នំពេញ** | **4.60** | **1.23** | **0.49** |
| ភ្នំពេញ | 4.60 | 1.23 | 0.49 |
| **ii) តំបន់វាលទំនាប** | **32.50** | **7.62** | **2.65** |
| កំពង់ចាម | 37.04 | 9.28 | 3.34 |
| កណ្តាល | 22.24 | 4.81 | 1.68 |
| ព្រៃវែង | 37.20 | 8.09 | 2.65 |
| ស្វាយរៀង | 35.93 | 8.35 | 2.75 |
| តាកែវ | 27.71 | 6.31 | 2.09 |
| **iii) តំបន់ទន្លេសាប** | **42.66** | **12.09** | **4.74** |
| បន្ទាយមានជ័យ | 37.15 | 9.82 | 3.58 |
| បាត់ដំបង | 33.69 | 7.94 | 2.65 |
| កំពង់ធំ | 52.40 | 15.55 | 6.23 |
| សៀមរាប | 51.84 | 17.31 | 7.46 |
| កំពង់ឆ្នាំង/ពោធិសាត់ | 39.57 | 10.35 | 3.78 |
| **iv) តំបន់ឆ្នេរ** | **28.80** | **6.11** | **2.02** |
| កំពត | 29.96 | 6.60 | 2.30 |
| ក្រុងព្រះសីហនុ/កែប/កោះកុង | 23.18 | 4.60 | 1.38 |
| **v) តំបន់ខ្ពង់រាប/ភ្នំ** | **51.78** | **15.47** | **6.22** |
| កំពង់ស្ពឺ | 57.22 | 16.98 | 6.72 |
| ខេត្តផ្សេងៗ[1] | 46.11 | 13.20 | 4.98 |
| **កម្ពុជា** | **35.13** | **9.19** | **3.45** |

**កំណត់ចំណាំ ១:** ខេត្តទាំងឡាយរួមមាន ក្រចេះ មណ្ឌលគិរី ព្រះវិហារ រតនគិរី ស្ទឹងត្រែង ឧត្តរមានជ័យ និងប៉ៃលិន ។ ដោយសារសំណាកគំរូមានចំនួនកំរិត ដើម្បីផ្តល់ការប៉ាន់ស្មានស្ថិតិសំខាន់ដោយឡែក ការប៉ាន់ស្មានបានផ្តល់ជាក្រុមនៃខេត្ត ។ ភាពក្រីក្របាន់ស្មាននៅក្នុងតារាងនេះត្រូវផ្អែកលើ សំណាកគំរូ១៥ខែពេញនៃការអង្កេតសេដ្ឋកិច្ចសង្គមកិច្ច ២០០៣-២០០៤ មិនមែនសំណាកគំរូ១២ ខែនៃប្រក្រតិទិនឆ្នាំ២០០៤ទេ។

**ប្រភព:** J.C. Knowles,,គំរូថ្មីមួយនៃភាពក្រីក្របាន់ស្មានសំរាប់កម្ពុជាឆ្នាំ១៩៩៣/៩៤ ទៅ ២០០៤ របាការណ៍សំរាប់អង្គភាពប្រទេស EAS នៃធនាគារពិភពលោក,២០០៥ និងស្ថានភាពនៃភាពក្រីក្រមួយនៅកម្ពុជា២០០៤, ក្រសួងផែនការ, កុម្ភៈ២០០៦

## គ្រួសារក្រីក្រមាននាក់នៅក្នុងបន្ទុកច្រើននិងទំហំគ្រួសារធំ

៣៧. សន្ទស្សន៍ភាពក្រីក្រខ្ពស់ខ្លាំង និងចំនួនច្រើននៃអ្នកក្ររស់នៅក្នុងគ្រួសារដែលមានមេគ្រួសារដឹកនាំដោយមនុស្សអាយុរវាង ៣០ទៅ៥០ឆ្នាំ ។ ដូចបង្ហាញនៅក្នុងរូបភាពទី៩ មេគ្រួសារទាំងបុរសនិងស្ត្រីមានពិសោធន៍ក្នុងអត្រាភាពក្រីក្រដូចគ្នានៅកម្ពុជា ។ ពុំមានភាពខុសគ្នាច្រើនដែលកើតមានក្នុងអត្រាភាពក្រីក្រ ចំពោះស្ថានភាពអាពាពិពារណ៍ ជនជាតិភាគតិចឬភាពពិការនៃមេគ្រួសារទេ ។ គ្រួសារក្រីក្រតែងតែមានអ្នកនៅក្នុងបន្ទុកច្រើន និងមានគ្រួសារធំ ។ សន្ទស្សន៍ភាពក្រីក្រកើនឡើងខ្លាំងសំរាប់គ្រួសារដែលមានទំហំលើសពី ៥ នាក់ ។

រូបភាពទី ៩: ភាពក្រីក្របាន់ស្មានតាមភេទនៃមេគ្រួសារឆ្នាំ២០០៤

(ភាគរយ)




ប្រភព: J.C. Knowles,,គំរូថ្មីមួយនៃភាពក្រីក្របាន់ស្មានសំរាប់កម្ពុជាឆ្នាំ១៩៩៣/៩៤ ទៅ ២០០៤ របាការណ៍សំរាប់អង្គភាពប្រទេស EAS នៃធនាគារពិភពលោក,២០០៥ និងស្ថានភាពនៃភាពក្រីក្រមួយនៅកម្ពុជា២០០៤, ក្រសួងផែនការ, កុម្ភៈ២០០៦

## ការអប់រំកាត់បន្ថយភាពក្រីក្រ

៣៨. អត្រាភាពក្រីក្រខ្ពស់ខ្លាំងក្នុងចំណោមអ្នកដែលមានមេគ្រួសារមានការអប់រំតិចតួចឬគ្មាន ។ ឆ្នាំនៃការសិក្សានិងអក្ខរកម្មនៃមេគ្រួសារមានការពាក់ពន្ធ័ខ្លាំងទៅនឹងភាពក្រីក្រ ។ នេះបង្ហាញពីការខ្វះខាតនៃធនធានមនុស្សទៅលើផ្នែកមួយនៃជនក្រីក្រ និងបញ្ចេញឱ្យឃើញពីសារៈសំខាន់នៃការវិនិយោគក្នុងធនធានមនុស្សដែលជាមធ្យោបាយមួយមានប្រសិទ្ធភាព នៃការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រនៅកម្ពុជា ។

## រូបភាពទី១០: ភាពក្រីក្រតាមកំរិតនៃការអប់រំរបស់មេគ្រួសារ ឆ្នាំ ២០០៤

(ភាគរយ)




<u>**ប្រភព:**</u> J.C. Knowles,,គំរូថ្មីមួយនៃភាពក្រីក្របាន់ស្មានសំរាប់កម្ពុជាឆ្នាំ១៩៩៣/៩៤ ទៅ ២០០៤ របាការណ៍សំរាប់អង្គភាពប្រទេស EAS នៃធនាគារពិភពលោក.២០០៥ និងស្ថានភាពនៃភាពក្រីក្រមួយនៅកម្ពុជា២០០៤. ក្រសួងផែនការ. កុម្ភ:២០០៦

### ការកំណត់កសិកម្មគឺមានសារៈសំខាន់ខ្លាំង

**៣៩.** ក្នុងករណីការងារតាមផ្នែក សន្ទស្សន៍ភាពក្រីក្រគឺខ្ពស់ ក្នុងចំណោមមេគ្រួសារដែលរកបានប្រាក់សំរាប់ការរស់នៅពីជីករ៉ែ កសិកម្មនិងកម្មករសាងសង់ ។ ការកំណត់ការអភិវឌ្ឍន៍កសិកម្មគឺមានសារៈសំខាន់ខ្លាំងដោយសារវាតំណាងឱ្យ៦៣ ភាគរយនៃចំនួនសរុបនៃជនក្រីក្រក្នុងប្រទេស ។

**៤០.** បើគិតពីស្ថានភាពនៃការងារ សន្ទស្សន៍ភាពក្រីក្រគឺខ្ពស់ខ្លាំងក្នុងចំណោមមេគ្រួសារដែលជាអ្នកបំរើនៅក្នុងផ្ទះ បន្ទាប់មកគឺកសិករដែលមានមុខរបរខ្លួនឯងនិងអ្នកគ្មានការងារធ្វើ ។ កសិករដែលមានមុខរបរខ្លួនឯងគឺជាក្រុមមួយធំបំផុត ៤៨ ភាគរយនៃចំនួនជនក្រីក្រសរុប ។ ដូច្នេះផ្លូវមួយដែលប្រកបដោយប្រសិទ្ធភាពខ្ពស់សំរាប់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាគឺពន្លឿន (កសិកម្ម) កំណើននៅជនបទ ដែលនឹងជួយផ្តល់ផលប្រយោជន៍លើសលប់ដល់ជនក្រីក្រភាគច្រើន ។

### ប្រអប់ទី២: ជំរុញកំណើនសេដ្ឋកិច្ចដែលមានមូលដ្ឋានទូលំទូលាយនៅកម្ពុជា

ចាប់តាំងពីឆ្នាំ ១៩៩៤ កម្ពុជាបានសម្រេចកំណើនសេដ្ឋកិច្ចក្នុងអត្រាមួយខ្ពស់ ជាមធ្យមប្រហែល ៧ភាគរយតាមរយៈការពង្រីកយ៉ាងឆាប់នៃកម្មនសាលកាត់ដេរ និងទេសចរណ៍ ។ ចំណែកការពន្លឿនទៅអនាគតប្រភព ដែលមានស្រាប់នៃកំណើនគឺជាអាទិភាព កម្ពុជាត្រូវការដែរដើម្បីពង្រីកប្រភពនៃកំណើនឱ្យបានច្រើនទៅតំបន់ជនបទ ដើម្បីបង្កើនអត្រានៃការកាត់បន្ថយភាពក្រីក្រ ។ ការធ្វើឱ្យមានកំណើនសេដ្ឋកិច្ចនៅជនបទ គឺបានមកពីសកម្មភាពកសិដ្ឋាននិងមិនមែនកសិដ្ឋាន ជាការចំរុះគ្នាមួយដែលត្រូវការចាំបាច់ដើម្បីការកាត់បន្ថយភាពក្រីក្រឱ្យមាននិរន្តភាព ក្នុងរយៈ

ពេលទសវត្សរ៍ខាងមុខ ។

នៅកម្ពុជា ការបង្កើនចំណូនកសិកម្មត្រូវការសកម្មភាពទាំងឡាយក្នុងផ្នែកគន្លឹះខ្លះៗ ដូចជាបង្កើនផលិតភាពកសិផល (ពិសេសស្រូវ) តាមរយៈការប្រើប្រាស់ឱ្យបានល្អប្រសើរប្រភេទផ្សេងនៃពូជដែលបានកែលម្អ និងធាតុផ្សេងទៀតដូចជាដីសមស្របនិងការគ្រប់គ្រងសត្វចង្រៃ និងការត្រួតពិនិត្យទឹកឱ្យបានល្អពិសេសតាមរយៈធារាសាស្ត្រធុនតូច ។ បង្កើនផលិតកម្ម ចិញ្ចឹមសត្វនិងត្រីក៏មានសារៈសំខាន់ដែរ ហើយការចិញ្ចឹមនេះត្រូវការសេវាបច្ចេកទេសដែលបានកែលម្អ សំរាប់សុខភាពសត្វនិងការស្រាវជ្រាវត្រី ការថែរក្សានិងការគ្រប់គ្រង ។ ការគាំទ្រសំរាប់ការពង្រីកការទទួលបានស្ថាប័នហិរញ្ញវត្ថុនៅជនបទត្រឹមត្រូវ ដែលនឹងមានសារៈសំខាន់សម្រាប់កសិករនិងសហគ្រិនជនបទ ដើម្បីពង្រីកទំហំនៃប្រតិបត្តការរបស់គាត់ និងធ្វើឱ្យមានច្រើនមុខផ្សេងៗគ្នា ឆ្ពោះទៅរកការចំណេញឱ្យបានច្រើន និងនិរន្តភាពសកម្មភាព ។ ដូចគ្នាដែរ ការសម្រួលឧបសគ្គដីធ្លីនឹងទាមទារឱ្យមានការខិតខំប្រឹងប្រែងចុះបញ្ជីដីធ្លី ដែលជាផ្នែកមួយនៃការបង្កើតឱ្យមាន កម្លាភាព និងសុវត្ថិភាពទីផ្សារដី ។

សេដ្ឋកិច្ចមិនមែនកសិដ្ឋាននៅជនបទរួមមាន ពាណិជ្ជកម្ម ការដឹកជញ្ជូន ការកែឆ្នៃ កម្មន្តសាលខ្នាតតូច ការលក់រាយនិងសេវាកម្ម និងសកម្មភាពដូចគ្នាផ្សេងទៀតដែលមានសក្តានុពលទូលំទូលាយ សំរាប់ឱ្យមានកំណើនខ្លាំង និងកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័សនៅកម្ពុជា ។ កម្ពុជាត្រូវការដើម្បីទទួលយក គោលនយោបាយសមស្របដើម្បីប្រមូលផលធានលើសក្តានុពលទាំងនេះ ។ ក្នុងបរិបទនេះ គោលនយោបាយទាំងឡាយដែលមានទិសដៅដើម្បីបង្កើនទ្រព្យរូបវន្តនៃជនក្រីក្រដូចជាដីធ្លី ឥណទាននិងហេដ្ឋារចនាសម្ពន្ធ័ជនបទ នឹងទៅជាផ្នែកមួយនៃការជំរុញកំណើនឱ្យបានឆាប់រហ័សនៃផ្នែកជនបទ ហើយក៏ដូចជាសេដ្ឋកិច្ចទាំងមូល ។

<u>ប្រភព:</u> ស្ថានភាពនៃភាពក្រីក្រមួយនៅកម្ពុជាឆ្នាំ២០០៤, ក្រសួងផែនការ, កុម្ភៈ២០០៦

## បញ្ហាភាគក្រីក្ររងគ្រោះក្នុងផ្លូវជាច្រើន

៤១, តាមរយៈបញ្ហាភាពចំណាយប្រើប្រាស់ សូចនាករសង្គមកិច្ចនៅកំរិតគ្រួសារខ្លះ បង្ហាញពីសភាពការណ៍រងគ្រោះខ្លាំងនៃបញ្ហាភាគក្រីក្រ ។ បញ្ហាភាគក្រីក្ររស់នៅក្នុងផ្ទះតូចនិងមានគុណភាពទាបនិងមានបន្ទប់តិចទទួលបានទឹកស្អាតនិងអនាម័យល្អប្រសើរតិចតួច ហើយពឹងផ្អែកខ្លាំងលើអុសសំរាប់ដុតនិងប្រេងកាតសំរាប់ដុតបំភ្លឺ ។ ចំពោះសភាពការណ៍នេះ គំលាតរវាងបញ្ហាភាគក្របំផុត ២០% និងបញ្ហាភាគមានបំផុត២០% គឺខ្ពស់ខ្លាំង ។ ប្រហែល ៩៤%នៃបញ្ហាភាគក្របំផុតបន្ទោរបង់តាមវាល (open land) ឬគ្មានបន្ទប់អនាម័យ ហើយជាង ៩៧%ប្រើអុសសំរាប់ដុត ។ តិចជាង ២% ក្នុងបញ្ហាភាគក្របំផុតបានទទួលអណ្តូងស្នប់ឬម៉ាស៊ីនទឹកសាធារណៈ ។ បញ្ហាភាគមានបំផុតមានទំហំគ្រួសារតូចនិងនាក់ក្នុងបន្ទុកទាប ។

៤២, ជាក់ស្តែងភាពខុសគ្នាកើតមានឡើង ក្នុងភាពជាម្ចាស់នៃរបស់ប្រើប្រាស់យូរអង្វែងក្នុងចំណោមបញ្ហាភាគចំណាយប្រើប្រាស់ផ្សេងៗ ។ ភាពជាម្ចាស់លើរបស់ផ្សេងៗដូចជាវិទ្យុ ទូរទស្សន៍ គ្រឿងសង្ហារឹមនិងសំភារៈក្នុងគ្រួសារគឺមានតិចតួចក្នុងចំណោមជនក្រីក្រ២០% ។

## ជនក្រីក្រតែងតែរស់នៅតំបន់ដាច់ស្រយាលនិងដាច់ពីគេ

៤៣.ជនក្រីក្រ ពិសេសបញ្ចូភាគក្របំផុត២០% តែងតែរស់នៅក្នុងតំបន់ដាច់ស្រយាលនិងដាច់ពីគេ ដែលនៅទីនោះជនក្រីក្រទទួលបានមានកំណត់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាមូលដ្ឋាន ។ ចម្ងាយទៅផ្លូវ ផ្សារ ចំណតរថយន្តនិងមូលដ្ឋានបន្តផ្សេងទៀត ហើយនិងសេវាគាំទ្របានកើនឡើងពីបញ្ចូភាគខ្ពស់ទៅបញ្ចូភាគទាប ។ បញ្ចូភាគក្របំផុត២០%គឺនៅដាច់ពីទីផ្សារនិងមូលដ្ឋានថែរក្សាសុខភាព ។

៤៤. ភូមិទាំងឡាយដែលជនក្រីក្ររស់នៅមានមូលដ្ឋានសុខាភិបាល និងអប់រំនៅឆ្ងាយ ។ ពិសេសសមានភាពខុសគ្នាខ្លាំងក្នុងការចូលរៀននៅសាលាមធ្យមសិក្សា និងរាល់ការផ្តល់សេវាសុខភាពទំនើប ។ ញ៉ាំងឱ្យជនក្រីក្រ ទទួលភាគច្រើនការផ្តល់សេវាមិនបានទទួលការបណ្តុះបណ្តាល និងសេវាសុខភាពបុរាណ ។

## ភាពខុសគ្នាខ្លាំងក្នុងសូចនាករអប់រំ

៤៥. សូចនាករពាក់ពន្ធ័និងការអប់រំបង្ហាញពីការប្រែប្រួលថេរជាមួយបញ្ចូភាគចំណាយប្រើប្រាស់ បង្ហាញពីសារៈសំខាន់នៃការអប់រំក្នុងការកាត់បន្ថយភាពក្រីក្រ ។ ភាពខុសគ្នាខ្លាំងកើតមានឡើងក្នុងសូចនាករអប់រំក្នុងចំណោមបញ្ចូភាគទាំងឡាយ ។ ភាពខុសគ្នាក្នុងសមាមាត្រ ការចុះឈ្មោះចូលរៀនពិតគួឱ្យចាប់អារម្មណ៍ខ្លាំងជាងភាពខុសគ្នាក្នុងសមាមាត្រចុះឈ្មោះចូលរៀនដុល ពិសេសបង្ហាញនិន្នាការនៃកុមារក្រីក្រចាប់ផ្តើមចូលរៀននៅអាយុមួយយឺត ។ លក្ខណៈរំខានមួយខ្លាំងពីចំណុចសមភាពចូលរួម គឺភាពខុសគ្នាដ៏ធំក្នុងចំនួនការចំណាយរបស់ឪពុកម្តាយ ក្នុងការចុះឈ្មោះចូលរៀនរបស់កុមារម្នាក់ ។ ចំនួនតឺជិត ២៥ ដងក្នុងមួយឆ្នាំធំជាងសំរាប់កុមារក្នុងបញ្ចូភាគមានបំផុត ជាងសំរាប់កុមារក្នុងបញ្ចូភាគក្របំផុត ។

ប្រអប់ទី៣: ការវិនិយោគក្នុងធនធានមនុស្ស-ការអប់រំ

ការអភិវឌ្ឍន៏ធនធានមនុស្សតាមរយៈការវិនិយោគក្នុងការអប់រំ សុខាភិបាលនិងអាហារូបត្ថម្ភ ជាសរសរទ្រូងនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល-មានផលប៉ះពាល់សំខាន់លើការកាត់បន្ថយភាពក្រីក្រ ។

សមិទ្ធិផលអប់រំរបស់កម្ពុជាក្នុងទសវត្សរ៍កន្លងមកគួរឱ្យកោតសរសើរ ។ ការផ្តោតលើការអប់រំបថមសិក្សា តាមរយៈការបង្កើនចំណាយសាធារណៈ បានបង្កើនអត្រាចុះឈ្មោះចូលរៀននៅបថមសិក្សា ពិសេសឆាប់រហ័សក្នុងចំណោមស្ត្រីនិងកុមារពីគ្រួសារក្រីក្រ ។ ម្យ៉ាងទៀតផ្នែកចាប់អារម្មណ៍ខ្លះនៅតែកើតមានដូចជា (១)ការរីកឡើងការចូលរៀនយឺតក្នុងប្រពន្ធ័អប់រំ ពិសេសក្នុងចំណោមកុមារពីបញ្ចូភាគក្រីក្រ ដែលកាត់បន្ថយសក្តានុពលចុះឈ្មោះចូលរៀននិងការចូលរៀន, និង(២)កំរិតទាបនៃការចុះឈ្មោះចូលរៀនមិនអាចពន្យល់ពេញលេញដោយ ពលកម្មកុមារតែឯងដោយសារមួយផ្នែកធំនៃកុមារក្រីក្រដែលមិនបានធ្វើការងារ ក៏មិនដែលចុះឈ្មោះចូលរៀនដែរ ។ នេះអាចពន្យល់មួយផ្នែកដោយតម្លៃមិនរៀបរយ និងគុណភាពទាបនៃការអប់រំ ។ ទោះបីតម្លៃផ្ទាល់នៃការអប់រំ បានថយចុះការចំណាយក្រៅហោរប៉ៅនៅតែបន្ត គឺជារបាំងមួយរារាំងការចូលសាលានៃកុមារពីគ្រួសារក្រីក្រ ។

ស្របជាមួយការកើនឡើងខ្លាំងចំណាយសាធារណៈលើផ្នែកអប់រំ អាទិភាពគឺដើម្បីទទួលយកគោលនយោបាយទាំងឡាយ ដើម្បីធ្វើឱ្យប្រសើរឡើងឱកាសសំរាប់ការអប់រំនិងសមិទ្ធិផល ពិសេសសំរាប់ជនក្រីក្រ ។

ប្រភព: ស្ថានភាពនៃភាពក្រីក្រមួយនៅកម្ពុជាឆ្នាំ២០០៤, ក្រសួងផែនការ, កុម្ភៈ២០០៦

### ដីកសិកម្មគឺមានសារៈសំខាន់ខ្លាំង ប៉ុន្តែការទទួលបានប្រពន្ធ័ប្រឡាយមានកំរិត

៤៦. ដីកសិកម្មគឺជាប្រភពសំខាន់បំផុតសំរាប់គ្រួសារជនកម្ពុជាភាគច្រើន ពិសេសក្នុងចំណោមបញ្ចភាគក្របំផុត ។ ប្រហែល ៨៤%នៃប្រជាជនក្នុងបញ្ចភាគក្របំផុតរស់នៅក្នុងគ្រួសារទទួលកម្មសិទ្ធ ឬប្រតិបត្តការដីកសិកម្ម ។ ជាមួយការទទួលបានធារាសាស្រ្តមានកំរិតសំរាប់គ្រប់បញ្ចភាគទាំងអស់ វាមានកំរិតទាបសំរាប់បញ្ចភាគក្របំផុត ។

### ជនក្រីក្រមានដីសុវត្ថិភាពតិចតួច និងអាស្រ័យលើធនធានកម្មសិទ្ធរួម

៤៧. ក្នុងចំណោមជនក្រីក្រដែលមានកម្មសិទ្ធដី សុវត្ថិភាពដីកើនឡើងជាមួយបញ្ចភាគចំណាយប្រើប្រាស់ ។ មានតែ១៦%ក្នុងបញ្ចភាគក្របំផុតមានកម្មសិទ្ធដីកាន់កាប់ ។ បញ្ចភាគក្របំផុតបង្ហាញពីការពឹងពាក់ខ្ពស់របស់គាត់ខ្ពស់ទៅលើធនធានកម្មសិទ្ធរួមដូចជា ការនេសាទ ការប្រមូលអុស ការស្វែងរកចំណីឬបរបាញ់សត្វព្រៃជាប្រភពនៃជីវិតរស់នៅ ។

### ចំណូលពីប្រភពមិនមែនកសិកម្មកាត់បន្ថយភាពខាយរងគ្រោះ

៤៨. ទោះបី ចំណូលពីប្រភពមិនមែនកសិកម្មមានសារៈសំខាន់ខ្លាំងសំរាប់បញ្ចភាគមានបំផុត ប្រភពទាំងនេះកាត់បន្ថយជាសំខាន់ភាពក្រីក្រសំរាប់បញ្ចភាពក្របំផុត ។ ប្រភពខ្លះផ្តល់ចំណូលសំខាន់ និងសុវត្ថិភាពក្នុងការចំណាយប្រើប្រាស់ ហើយនឹងស្ថេរភាពធៀបនឹងផលិតកម្មកសិកម្ម ដែលមានការប្រែប្រួលខ្លាំងដោយសារគ្រោះរាំងស្ងួតនិងទឹកជំនន់ ។ ចំណូលពីប្រភពមិនមែនកសិកម្ម គឺជាផ្លូវសំខាន់ដែរសំរាប់បញ្ចភាគក្របំផុតដើម្បីដោះស្រាយហេតុការណ៍វិបត្តផ្សេងៗដូចជាការមានជម្ងឺ និងជួយជនក្រីក្រ ជៀសផុតពីការលក់ទ្រព្យឬធ្លាក់ក្នុងអន្ទាក់បំណុល ។ បញ្ចភាគក្របំផុតបង្ហាញភាពងាយរងគ្រោះច្រើនក្នុងគ្រប់រូបភាព ដូចជាកំរិតជំពាក់បំណុល អសន្តិសុខស្បៀងនិងកង្វះអាហារូបត្ថម្ភ ឈឺច្រើននិង មរណៈភាព និងប្រឈមច្បាប់មិនត្រឹមត្រូវនិងស្ថានភាពបញ្ហា បើធៀបជាមួយបញ្ចភាគមានបំផុត ។

### ជនក្រីក្រខាយរងគ្រោះច្រើន និងមានស្ថានភាពសុខភាពទាប

៤៩. បញ្ចភាគក្របំផុតមានបទពិសោធន៍សន្ទស្សន៍ខ្ពស់នៃភាពងាយរងគ្រោះ និងស្ថានភាពសុខភាពទាប ។ បញ្ចភាគមានបំផុតតែងប្រើការថែរក្សាសុខភាពញឹកញាប់ (ពិសេសការសំរាកពេទ្យ) និងចំណាយច្រើនក្នុងរយៈពេលនិមួយៗនៃការមានជម្ងឺ ។ សូចនាករសំរាប់ការថែរក្សាសុខភាពក្នុងចំណោមកុមារនិងមាតាក៏បង្ហាញដែរ ពីស្ថានភាពនៃបញ្ចភាគក្របំផុត ។

៥០. ការវិភាគពហុអថេរមួយបង្ហាញពីទំនាក់ទំនងសំខាន់នៃភាពក្រីក្រ និងចំណាយប្រើប្រាស់សំរាប់មនុស្សម្នាក់ ជាមួយនិងលក្ខណៈពិសេសនៃប្រជាសាស្រ្ត ពហុប្រភពចំណូល និងអថេរសេដ្ឋកិច្ចសង្គមកិច្ចផ្សេងៗទៀត ។ នេះបង្ហាញពីប្រភេទពហុទំហំនៃភាពក្រីក្រនៅកម្ពុជា ។

### ប្រអប់ទី ៤: សុខភាពនិងអាហារូបត្ថម្ភ

ក្នុងទសវត្សរ៍កន្លងមក កម្ពុជាបានធ្វើឱ្យមានជំហានល្អក្នុងការធ្វើឱ្យប្រសើរឡើងសុខភាពនិងអាហារូបត្ថម្ភរបស់ប្រជាជនខ្លួន ។ ជាមួយជោគជ័យ ក្នុងអត្រាចាក់ថ្នាំការពារកុមារ អាយុកាលជីវិតរស់នៅ មរណៈភាពទារកនិងកុមារ និងការទទួលបានទឹកស្អាតនិង អនាម័យល្អបានធ្វើឱ្យប្រសើរឡើងជានិច្ច ។ អត្រាកំណើនប្រជាជនបានថយចុះពី ២.៤៩% ក្នុងឆ្នាំ១៩៩៨ មក ១.៨១%ក្នុងឆ្នាំ២០០៤ និងអត្រាលទ្ធភាពផ្តល់កំណើតសរុបបានធ្លាក់ចុះមកប្រហែល ៣.៣ក្នុងឆ្នាំ ២០០៥ ។

ក្នុងពេលជាមួយ បញ្ហាប្រឈមធ្ងន់ធ្ងរក្នុងសុខភាពសាធារណៈស្ថិតនៅដដែល ។ មរណៈភាពមាតានិងអត្រាកង្វះអាហារូបត្ថម្ភរបស់កុមារនៅខ្ពស់ ។ ការឈឺស្លាប់ខ្លះនៅតែមាន និងភាពខុសគ្នាជាក់ស្តែងក្នុងការទទួលសេវាថែរក្សាសុខភាព នៅតែបន្តបែងចែកអ្នកក្រ និងក្រុមដែលគ្រាន់បើជាង បង្កើតឱ្យមានបញ្ហាប្រឈមក្នុងប្រព័ន្ធសុខាភិបាល ។ ទោះបីមានការកែលំអកន្លងមកក្នុងភាពទទួលបានមូលដ្ឋានសុខាភិបាល ការចំណាយក្នុងសុខភាពសាធារណៈនៅកម្ពុជា នឹងត្រូវមានការបែងចែកសារជាថ្មីឱ្យបានច្រើនក្នុងការអនុគ្រោះជនក្រីក្រ។ ឧទាហរណ៍ ការចំណាយបានកើនឡើងក្នុងការថែរក្សាកុមារ ផែនការគ្រួសារ ការត្រួតពិនិត្យជម្ងឺឆ្លង និងការថែរក្សាពេលមានផ្ទៃពោះវាហាក់ដូចផ្តល់ផលចំណេញដល់អ្នកក្រ។

អត្រាកង្វះអាហារូបមត្ថម្ភនៅកម្ពុជាគឺនៅខ្ពស់ខ្លាំង ប៉ុន្តែភាពជឿនលឿនច្រើនត្រូវបានធ្វើលើផ្នែកនេះក្នុងប៉ុន្មានឆ្នាំកន្លងមក ។ កុមារខ្វះអាហារូបត្ថម្ភ ពាក់ពន្ធ័ខ្លាំងជាមួយក៏រិតចំណូល ចំណូលទាបគឺជាកត្តាមួយក្នុងចំណោមកត្តាទាំងឡាយជាច្រើនដែលយកមកពន្យល់ ។ឧទាហរណ៍ទំនាក់ទំនងផ្លាស់ប្តូរឥរិយាបទ ( ផ្តល់ចំណេះដឹងដល់មាតា) គឺមានសារៈសំខាន់ខ្លាំងសំរាប់កាត់បន្ថយកង្វះអាហារូបត្ថម្ភ។ ការទទួលបានទឹកស្អាតនិងអនាម័យ មន្ទីរពេទ្យ និងគុណភាពនៃហេដ្ឋារចនាសម្ពន្ធ័ភូមិ គឺជាកត្តាសំខាន់ដែលពន្យល់ការប្រែប្រួលក្នុងស្ថានភាពអាហារូបត្ថម្ភតាមភូមិ ។

<u>ប្រភព:</u> ស្ថានភាពនៃភាពក្រីក្រមួយនៅកម្ពុជាឆ្នាំ២០០៤, ក្រសួងផែនការ, កុម្ភៈ២០០៦

## IV.ការពន្លឿនការកាត់បន្ថយភាពក្រីក្រ៖ ការសម្លឹងមើលចំពោះមុខ ការប្រយុទ្ធដែលមានមុខព្រួញច្រើនមួយគឺជាការចាំបាច់

៥១. របាយការណ៍ស្ថានភាពនៃភាពក្រីក្រនៅកម្ពុជាឆ្នាំ ២០០៤ ផ្តល់មួយចំនួននូវការយល់ដឹងជ្រៅ លើអ្វីដែលកម្ពុជាអាចពន្លឿនអត្រារបស់ខ្លួនក្នុងការកាត់បន្ថយភាពក្រីក្រ ដោយធ្វើឱ្យសំរេចបានកំណើនមួយដែលគាំទ្រអ្នកក្រច្រើន តាមរយៈការទទួលយកនូវគោលនយោបាយទាំងឡាយសមស្រប ។

៥២. ការប្រែប្រួលមួយក្នុងយុទ្ធសាស្ត្រចំណូលដែលមានស្រាប់ និងទ្រព្យកាន់កាប់ដោយជនក្រីក្របញ្ជាក់ច្បាស់ថា ការព្យាបាលតែមួយមិនគ្រប់គ្រាន់ដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជាទេ ។ សេចក្តីត្រូវការគឺដើម្បីផ្តល់ការប្រយុទ្ធមួយដែលមានពហុមុខព្រួញលើភាពក្រីក្រ ។

## ភាពក្រីក្រកម្ពុជាគឺដូចគ្នាប្រទេសដែលមានចំណូលទាបផ្សេងទៀត

៥៣, ស្ថានភាពនៃជនក្រីក្រកម្ពុជាគឺមិនខុសគ្នាខ្លាំងពីជនក្រីក្រក្នុងប្រទេសទាំងឡាយដែលមានចំណូលទាបទេ ។ ភាពក្រីក្រក៏ដូចភាពក្រីក្រម្ហូបអាហារ គឺខ្ពស់នៅតំបន់ជនបទ ជាងនៅភ្នំពេញនិងទីប្រជុំជនផ្សេងទៀត ។ បន្ថែមលើការរស់នៅជនបទជនក្រីក្រតែងតែមានកំរិតការអប់រំទាប ការទទួលមានកំរិតដីនិងទ្រព្យផលិតផ្សេងទៀត និងប្រមូលផ្តុំលើការងារដែលមានកំរៃទាប ទាមទារកម្លាំងនិងមុខរបរមិនទាក់ទាញសង្គម។ ទាំងនៅទីប្រជុំជននិងជនបទ ជនក្រីក្របានទទួលតិចតួចសេវាទំនើបនិងជាទីគាប់ចិត្ត ។ គាត់រស់នៅក្នុងផ្ទះទ្រុឌទ្រោម មិនបានឬទទួលមានកំរិតសេវាមូលដ្ឋានដូចជាទឹកស្អាតនិងអនាម័យល្អ ។ ជនក្រីក្រតែងរស់នៅក្នុងគ្រួសារ មានសមាជិកច្រើន កូនច្រើននិងមេគ្រួសារមានការអប់រំតិច។ គាត់បានទទួលតិចតួចសេវាសាធារណៈ។

## ផ្នែក គន្លឹះ៣៖

៥៤, ទ្រព្យចំបងរបស់ជនក្រីក្រកម្ពុជាគឺកំម្លាំងពលកម្ម ។ ម្យ៉ាងទៀតតម្រូវការដើម្បីវិនិយោគគ្រប់គ្រាន់ និងការកសាងដ៏មានប្រសិទ្ធភាពធនធានមនុស្សនិងជំនាញគឺជាការត្រឹមត្រូវ ។ ដោយសារជាង ៩០%នៃជនក្រីក្ររស់នៅតំបន់ជបបទ ការពន្លឿនកំណើនកសិកម្ម តាមរយៈការធ្វើឱ្យរីតតែខ្លាំងឡើង និងការឱ្យមានដំណាំកសិកម្មច្រើនមុខគឺមានសារៈសំខាន់ ។ ដូចគ្នាដែរគ្រួសារក្រីក្រនឹងទទួលផលពីការពង្រីកឱកាសទាំងឡាយសំរាប់ការងារ ក្នុងផ្នែកមិនមែនកសិដ្ឋាន ។ ការឆាប់ធ្វើឱ្យប្រសើរឡើងក្នុងហេដ្ឋារចនាសម្ព័ន្ធជនបទគឺមានសារៈសំខាន់ ទាំងសំរាប់ការអភិវឌ្ឍន៍ផ្នែកកសិកម្មទំនើបមួយ និងសំរាប់ការធ្វើឱ្យមានសន្ទុះកំណើនផ្នែកមិនមែនកសិដ្ឋាន ។

### *តម្រូវការដើម្បីដោះស្រាយប្រភពនៃការកើនឡើងវិសមភាព*

៥៥, បន្ថែមទៅលើអត្រារបស់វា ផលប៉ះពាល់នៃកំណើនសេដ្ឋកិច្ចលើភាពក្រីក្រ គឺអាស្រ័យលើអ្វីអាចកើតមានឡើងទៅលើភាពក្រីក្រ ។ ជាសំខាន់ត្រូវស្គាល់ពីគំរូនៃកំណើនកម្ពុជាពីមុន ដែលមាននិន្នាការបង្កើតវិសមភាពខ្ពស់ ពិសេសនៅតំបន់ជនបទ ។ ជាមួយនិងមួយភាគធំនៃជនក្រីក្ររស់នៅតំបន់ជនបទ វាមានសារៈសំខាន់ណាស់សំរាប់កម្ពុជា ដើម្បីពិនិត្យបញ្ហាវិសមភាពចំពោះមុខ និងកំណត់ និងដោះស្រាយប្រភពនៃការកើនឡើងវិសមភាពដែលគ្របដណ្តប់គ្រប់ទំហំទាំងឡាយ ដូចជាការរីករាលដាលមិនធម្មតានៃឱកាសសេដ្ឋកិច្ចនិងសង្គមកិច្ច ការបែងចែកដែលលំអៀងនៃហិរញ្ញវត្ថុនិងធនធានមនុស្ស និងការកើនឡើងភាពក្រីក្រក្នុងគ្រប់ផ្នែកផ្សេងៗនៃជីវិត ។

### *ការបង្កើត និងរក្សាបរិដ្ឋានមួយដែលអាចធ្វើទៅបាន*

៥៦, ជោគជ័យក្នុងការកាត់បន្ថយភាពក្រីក្រ និងធ្វើឱ្យប្រសើរឡើងកំរិតស្តង់ដារស់នៅរបស់គ្រប់ជនកម្ពុជាគឺអាស្រ័យទៅលើការផ្តល់ការយកចិត្តទុកដាក់ ដើម្បីបង្កើតនិងរក្សាបរិយាកាសមួយដែលអាចធ្វើទៅបាន

សំរាប់កំណើនឆាប់និងគាំទ្រអ្នកក្រ ។ ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវនិងអភិបាលកិច្ចល្អ គឺជាតម្រូវការដំបូងសំខាន់សំរាប់បង្កើតបរិដ្ឋានមួយដូចនេះ ។ ការកែទំរង់ក្នុងគ្រប់ផ្នែកទាំងអស់ ពិសេសការកែលម្អក្នុងរដ្ឋបាលសាធារណៈ និងការផ្តល់អំណាចច្បាស់លាស់ទៅឱ្យស្ថាប័នមូលដ្ឋាន នឹងបង្កើតបរិដ្ឋានទូលំទូលាយមួយដែលក្នុងនោះជនក្រីក្រអាចទទួលឱកាស និងកសាងទ្រព្យយោងទៅតាមសេចក្តីត្រូវការរបស់គាត់ ដើម្បីគេចឱ្យផុតពីភាពក្រីក្រ ។

៥៧. នៅក៏រិតអភិវឌ្ឍន៏បច្ចុប្បន្ន ការបារម្ភសំខាន់មួយសំរាប់កម្ពុជាគឺដើម្បីធានាឱ្យមានភាពស៊ីសង្វាក់គ្នា និងទទួលបានភ្លាម និងផ្តល់ផលល្អដល់លទ្ធផលនៃការកាត់បន្ថយភាពក្រីក្រ ។ នេះអាចសំរេចបានតាមរយៈសកម្មភាពសំខាន់ៗ លើអ្វីដែលត្រូវបានសម្រេចកន្លងមក ក្នុងការកាត់បន្ថយភាពក្រីក្រ កសាងស្ថាបន័សេដ្ឋកិច្ចសង្គមកិច្ច សំរាប់ការពន្លឿនកំណើនដែលគាំទ្រអ្នកក្រ និងការចម្លងការអនុវត្តល្អៗ ។ ឆ្លងតាមការប្រែប្រួលក្នុងកំណត់ដៅ ក្នុងការអនុវត្តនិងក្នុងគោលនយោបាយ ទាំងអស់នេះនឹងនាំមកនូវកំណើនមានសុវត្ថភាពផ្តល់ផលប្រយោជន៏ដល់ជនក្រីក្រនៅជនបទ ។ នេះនឹងធានាដែរឱ្យមានចលនាលឿន និងថេរឆ្ពោះទៅរកសមភាពដ៏ល្អ និងយុត្តិធមិសំរាប់គ្រប់ជនកម្ពុជា ។

## ប្រអប់ទី៥: ការសម្លឹងមើលទៅមុខ-ការពន្លឿនការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា

របាយការណ៏ស្តីពីស្ថានភាពនៃភាពក្រីក្រនៅកម្ពុជាឆ្នាំ២004 ផ្តល់នូវការយល់ដឹងជ្រៅលើ តើធ្វើដូម្តេចកម្ពុជាអាចពន្លឿនអត្រានៃការកាត់បន្ថយភាពក្រីក្ររបស់ខ្លួន តាមរយៈការសំរេចបានកំណើនមួយដែលគាំទ្រអ្នកក្រច្រើន ដោយទទួលយកគោលនយោបាយទាំងឡាយដែលសមស្រប ។

ការស្ថិតនៅនៃភាពមានការផ្លាស់ប្តូររឿយៗច្រើនក្នុង យុទ្ធសាស្រ្តចំណូល និងទ្រព្យកាន់កាប់ដោយជនក្រីក្រ ធ្វើឱ្យដឹងច្បាស់ថាការព្យាបាលតែមួយមិនអាចគ្រប់គ្រាន់ ដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ហើយសេចក្តីត្រូវការគឺដើម្បីផ្តល់នូវការប្រយុទ្ធពហុមុខព្រួញលើភាពក្រីក្រ ។

ទ្រព្យចំបងរបស់ជនក្រីក្រគឺកម្លាំងពលកម្ម ដូច្នេះសេចក្តីត្រូវការដើម្បីវិនិយោគសមស្រប និងប្រកបដោយប្រសិទ្ធភាពក្នុងការកសាងធនធានមនុស្សនិងជំនាញគឺត្រឹមត្រូវ ។ ដោយសារជាង៩១%នៃជនក្រីក្ររស់នៅតំបន់ជនបទ ការពន្លឿនកំណើនកសិកម្ម ទាំងតាមរយៈប្រពលវប្បកម្មនិងធ្វើឱ្យមានដំណាំច្រើនមុខគឺមានសារៈសំខាន់ណាស់ ។ គ្រួសារក្រីក្រនឹងទទួលផលពីការពង្រីកឱកាសការងារក្នុងផ្នែកមិនមែនកសិដ្ឋាននៅជនបទ ។ ការកែលម្អឆាប់រហ័ស្នុងហេដ្ឋារចនាសម្ពន្ឋ័ក្នុងជនបទគឺមានសារៈសំខាន់ ទាំងសំរាប់ការអភិវឌ្ឍន៏ផ្នែកកសិកម្មសម័យមួយ និងសំរាប់ធ្វើឱ្យមានសន្ទុះកំណើនមិនមែនកសិកម្ម។

ជោគជ័យក្នុងផ្នែកទាំងអស់នេះ អាស្រ័យលើការផ្តល់ការយកចិត្តទុកដាក់ ដើម្បីបង្កើតនិងរក្សាបរិដ្ឋានឱ្យបានច្រើនតាមតែអាចធ្វើទៅបានសំរាប់កំណើនឆាប់រហ័ស ។ ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចត្រឹមត្រូវនិងអភិបាលកិច្ចល្អ គឺជាតម្រូវការសំខាន់ដំបូង សំរាប់បង្កើតបរិដ្ឋានដូចនេះ។ ការកែទំរង់គ្រប់ផ្នែក ពិសេសការធ្វើឱ្យប្រសើររដ្ឋបាលសាធារណៈ និងការផ្តល់អំណាចប្រកបដោយកំល្លាភាពទៅដល់ស្ថាប័នមូលដ្ឋាន នឹងបង្កើតបរិដ្ឋានទូលំទូលាយមួយ

ដែលក្នុងនោះជនក្រីក្រអាចមានឱកាសចូលរួម និងកសាងទ្រព្យយោងទៅតាមសេក្តីត្រូវការរបស់គាត់ និងរត់គេចពីភាពក្រីក្រ ។

**ប្រភព:** ស្ថានភាពនៃភាពក្រីក្រមួយនៅកម្ពុជាឆ្នាំ២០០៤, ក្រសួងផែនការ, កុម្ភៈ២០០៦

*គឺមានសារៈសំខាន់ណាស់សំរាប់កំណើនដើម្បីទៅជនក្រីក្រ និងពង្រីកឱកាសរបស់គាត់*

៥៨, សំរាប់ទសវត្សរ៍ខាងមុខ កម្មវត្ថុសំខាន់នៃចក្ខុវិស័យរបស់កម្ពុជានឹងត្រូវធានាថាកំណើនបានដល់ជនក្រីក្រ និងពង្រីកឱកាសរបស់គាត់ ។ ត្រឡប់មកវិញ នេះទាមទារគោលនយោបាយទាំងឡាយដែលធានាថាជនក្រីក្រមានទ្រព្យ ការអប់រំ សុខភាពល្អ ទទួលប្រភពនិងទីផ្សារ សម្លេងនិងអំណាច និងការចូលរួមក្នុងការធ្វើសេចក្តីសំរេចចិត្ត ដើម្បីឱ្យមានធនធានសំរាប់ការពង្រីកឱកាសនៃកំណើន។ ដូច្នេះការប្រែក្លាយយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា ទៅជាសកម្មភាពសក្តិសិទ្ធិនិងច្បាស់លាស់ ត្រូវការការកំណត់និងគិតទុកជាមុន ទាំងពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍របស់ខ្លួន ។